ក

## មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៣-០១-២០០២ | ព្រះរាជក្រឹត្យ/នស/រកត/០១០២/០១៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ង៉ ហុងយ៉ាវ** (NG HUNG YAU សញ្ជាតិដើមចិន | ២០៣ |
| ២៣-០១-២០០២ | ព្រះរាជក្រឹត្យ/នស/រកត/០១០២/០១៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ហួង ទៀនហ្វា** (HUANG TIEAN FA ) សញ្ជាតិដើមចិន | ២០៤ |
| ២៥-០១-២០០២ | ព្រះរាជក្រឹត្យ/នស/រកត/០១០២/០១៨ ស្តីពីការ តែងតាំងឯកឧត្តម ០៣ រូបជាសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ២០៥ |


## II- រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


| | | |
|---|---|---|
| ២៤-០១-២០០២ | អនុក្រឹត្យលេខ ០៦ អនក្រ .បក ស្តីពីប្រាក់បំណាច់សវនកម្មនិងប្រាក់ បំណាច់ផ្សេងៗរបស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការបុគ្គលិកអាជ្ញាធរ សវនកម្ម ជាតិ | ២០៧ |
| ២៤-០១-២០០២ | អនុក្រឹត្យលេខ ០៧ អនក្រ.បក ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា | ២០៩ |
| ២៤-០១-២០០២ | អនុក្រឹត្យលេខ ៤៤ អនក្រ .តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ២១៨ |
| ២៤-០១-២០០២ | អនុក្រឹត្យលេខ ៤៥ អនក្រ .តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ២១៩ |
| ២៤-០១-២០០២ | អនុក្រឹត្យលេខ ៤៦ អនក្រ .តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២២០ |
| ៣០-០១-២០០២ | អនុក្រឹត្យលេខ ៤៧ អនក្រ .តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២២២ |
| ៣០-០១-២០០២ | អនុក្រឹត្យលេខ ៤៨ អនក្រ .តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ២២៣ |


### ២_ សេចក្តីសំរេច


| | | |
|---|---|---|
| ២៤-០១-២០០២ | សេចក្តីសំរេចលេខ ០៧ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល | ២២៤ |
| ២៤-០១-២០០២ | សេចក្តីសំរេចលេខ ០៨ សសរ ស្តីពីការ គណៈកម្មការចំរុះ អចិន្ត្រៃយ៍សំរបសំរួលការងារ ទំនប់ ប្រឡាយនៅ តំបន់ព្រំដែនកម្ពុជា-វៀតណាម-ឡាវ-ថៃ | ២២៥ |

## ៣_សារាចរណែនាំ

២៤-០១-២០០២ សារាចរណែនាំលេខ ០១ សរណន របស់រាជរដ្ឋាភិបាល ២២៨

## III- ការងារបណ្ដាក្រសួង

### ១_ ទីស្ដីការគណៈរដ្ឋមន្ត្រី

២៣-០១-២០០២ សេចក្ដីជូនដំណឹងលេខ ១៣៥ សជណ.សរ ស្ដីពីលទ្ធផលសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០២ ២២៨ក

### ២_ ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ប្រកាស

១៥-០១-២០០២ ប្រកាសលេខ ០៧០ សហវ.ប្រក ស្ដីពីការចាត់តាំងមន្ត្រីរាជការជាជំនួយការក្នុងកម្មវិធីពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២២៩

២២-០១-២០០២ ប្រកាសលេខ ១៧៤ សហវ.ឧ ហ ស្ដីពីការប្រកាសបន្ថែម ប្រកាសលេខ ៨៧៥-៨៧៦-៨៧៧ និង ៨៧៨ សហវ ចុះថ្ងៃទី ២៦ខែវិច្ឆិកា ឆ្នាំ ២០០១ ស្ដីពីការដាក់អាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនភ្នាក់ងារ **ការមិនភូ** ស្ថិតក្នុងភាពផុតសុពលភាព ២៣២

២២-០១-២០០២ ប្រកាសលេខ ១៧៥ សហវ.ពដ.ប្រក ស្ដីពីការគ្រប់គ្រងនិងប្រមូលអាករសំរាប់ បំភ្លឺសាធារណៈ ២៣៤

២៤-០១-២០០២ ប្រកាសលេខ ១៧៦ សហវ.ឧហ ស្ដីពីបទប្បញ្ញត្តិដែលត្រូវអនុវត្តចំពោះភ្នាក់ងារធានា រ៉ាប់រងនិងជើងសារធានារ៉ាប់រង ២៣៧

២៤-០១-២០០២ ប្រកាសណែនាំលេខ១៧៧សហវ.ថវស្ដីពីការអនុវត្តន៍ថវិកាខេត្ត-ក្រុងឆ្នាំ២០០២ ២៤២

២៥-០១-២០០២ ប្រកាសអន្តរក្រសួងលេខ២០៣ សហវ.អ ស្ដីពីការបន្ថែមទុនរបស់រដ្ឋ ក្នុងសហគ្រាសឱសថកម្ពុជា " ស.ឱ.ក" ២៤៦

២៣-០១-២០០២ សារាចរលេខ ០០១ សហវ.ថហ ស្ដីពីការណែនាំអនុវត្តថវិការដ្ឋឆ្នាំ ២០០២ ២៦៤

២៥-០១-២០០២ ប្រកាសលេខ ២០៤ សហវ.ស្ដីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ២៦៨

២៨-០១-២០០២ សេចក្ដីជូនដំណឹងលេខ ២៥២ សហវ.អ ស្ដីពីកម្មវិធីនៃកិច្ចប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុ ឆ្នាំ ២០០២ ២៧២

### ២_ ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៨-០១-២០០២ ប្រកាសលេខ ០២៣ Moc/M2002ស្ដីពីលទ្ធផលនៃការដេញថ្លៃកូតាសំរាប់នាំចេញសំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០២ ២៤៨

គ


## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

២៥-០១-២០០២ ប្រកាសលេខ ៣៨ បទ.ប្រក ស្តីពីការបង្កើតគណៈកម្មការរៀបចំប្រជុំស្តីពីការធ្វើអាជីវកម្មប្រៃសណីយ៍អាស៊ានលើកទី ៩ (9th ASEAN POSTAL BUSINESS MEETING) ២៥៤

## ៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២២-០១-២០០២ ប្រកាសលេខ ៧៨ អយក.ប្រក ស្តីពីការរៀបចំនិងការ ប្រព្រឹត្តិទៅនៃការប្រឡង សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ២៥៦

## ៥. ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

២៤-០១-២០០២ សេចក្តីជូនដំណឹងលេខ ០៩៧ សជណ ស្តីពីការអនុវត្តអនុក្រឹត្យលេខ ២៧ អនក្រ .បក ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០១ ២៦២

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០១៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ង៉ៃ ហុងយ៉ៅ (NG HUNG YAU ) សញ្ជាតិដើមចិន កើតថ្ងៃទី ០៣ សីហា ឆ្នាំ ១៩៥៧ នៅក្វាងចូវ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ខែ មករា ឆ្នាំ ២០០២*
*ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់*
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា**
**ជា ស៊ីម**

លេខ : ៧៥ ច.ល

៣.ស. ០២.០១.០០២

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០២
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០១៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

~~~~~~

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ហួង ទៀនហ្វា ( HUANG TIEN FA ) ហៅ ហួង ទ្រី (HUANG TRY) សញ្ជាតិដើមចិន កើតថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៥១ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ មករា ឆ្នាំ២០០២
ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា**

លេខ : ៧៦ ច.ល **ជា ស៊ីម**

ពរស. ០២.០១.០០២២

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ . ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០០២
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាវ៉ាឌី ឆាន់**
~~~~~~

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០១៥

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០១០០ / ០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង ឥស្សរជនចំនួន ០៣ រូប ជាសមាជិក គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដូចមានរាយនាមខាងក្រោម ៖

១-ឯកឧត្តម ញូង ស៊ាប

២-ឯកឧត្តម ម៉ក់ សម្បត្តិ

៣-ឯកឧត្តម ហង្ស ឡារ៉ាម៉ានី

**មាត្រា ២ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ មករា ឆ្នាំ ២០០២*

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

លេខ : ២៤ ច.ល

៣រស-០២-០១-០០៧៣

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែមករា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាខី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០១០២/០១៩

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០១០០ / ០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង ឥស្សរជនចំនួន ០៤ រូប មានឋានៈស្មើ **អគ្គនាយក** ដូចមានរាយនាម និងភារកិច្ចខាងក្រោម ៖

១-ឯកឧត្តម តិច ច័ន្ទតារា ជាប្រធានអនុគណៈកម្មាធិការទី១ នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

២-ឯកឧត្តម នូ ស្ថាបត្យា ជាប្រធានអនុគណៈកម្មាធិការទី២ នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

៣-ឯកឧត្តម ប៉ែន សិន ជាប្រធានអនុគណៈកម្មាធិការទី៣ នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

៤-ឯកឧត្តម អ៊ីវ កាន ជានាយកខុទ្ទកាល័យ នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ មករា ឆ្នាំ ២០០២*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

លេខ : ២៣ ច.ល

ដើម្បីចម្លងចែក

៣រល.០៧.០១.០០៧៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈារី តាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗ របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិក អាជ្ញាធរសវនកម្មជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ឆ្នាំ ២០០២ ។

-តាមសំណើរបស់អគ្គសវនករ

## <u>សំ រេ ច</u>

**មាត្រា ១ :** អនុក្រឹត្យនេះកំណត់ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិកអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ២ :** ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ បុគ្គលិកអាជ្ញាធរសវនកម្មជាតិត្រូវកត់ត្រាក្នុងជំពូក ១០ នៃមាតិកាថវិកាជាតិ ។

**មាត្រា ៣ :** អគ្គសវនករ អគ្គសវនកររង អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវបានទទួលប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗប្រចាំខែតាមការកំណត់ដូចខាងក្រោមចាប់ពីថ្ងៃទទួលភារកិច្ច :

- អគ្គសវនករត្រូវបាន : ៦.៣៣៧.០០០៛
- អគ្គសវនកររងត្រូវបាន : ៤.៩៣០.០០០៛
- អគ្គលេខាធិការត្រូវបាន : ៣.៦៤១.៦០០៛
- អគ្គលេខាធិការរងត្រូវបាន : ២.៩៨០.១០០៛

**មាត្រា ៤ :** ប្រាក់បំណាច់សវនកម្ម និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការ បុគ្គលិកអាជ្ញាធរសវនកម្មជាតិ ដែលមិនបានចែងក្នុងប្រការ ៣ ត្រូវស្ថិតនៅក្រោមការពិនិត្យ និងសំរេចរបស់អគ្គសវនករ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

បានជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រី
**អគ្គសវនករ**

**អ៊ិត ឈន**

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចមានមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ...០៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា

# " កម្ពុជា រី "

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០១

# សំរេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋឈ្មោះ **ក្រុមហ៊ុនធានារ៉ាប់រងបន្ត កម្ពុជា** ហៅកាត់ថា "**កម្ពុជា រី**" និងឈ្មោះជាភាសាអង់គ្លេស CAMBODIAN REINSURANCE COMPANY "CAMBODIA RE" ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**កម្ពុជា រី** មានទីស្នាក់ការនៅរាជធានីភ្នំពេញ អគារលេខ ២៨ កាច់ជ្រុងផ្លូវលេខ ១៣ និងលេខ ១០៦ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**កម្ពុជា រី** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាពផ្នែកបច្ចេកទេស ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ ។

**កម្ពុជា រី** ត្រូវស្ថិតក្រោមឥទ្ធិពលបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ហើយត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ២ .-**

**កម្ពុជា រី មានគោលដៅ និងភារកិច្ច ដូចខាងក្រោម :**

១- **កម្ពុជា រី** ធ្វើអាជីវកម្មធានារ៉ាប់រងបន្ត លើគ្រប់ប្រភេទហានិភ័យ រួមទាំងធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងលើអាយុជីវិត ។

២- អនុវត្តគ្រប់កិច្ចការដែលទាក់ទងដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងអាជីវកម្មធានារ៉ាប់រងបន្ត។

៣- ចូលរួមតាមគ្រប់មធ្យោបាយជាមួយសហគ្រាស ឬក្រុមហ៊ុននានាដែលកំពុងដំណើរការ ឬជាមួយក្រុមហ៊ុនដែលនឹងដំណើរការនាពេលខាងមុខ ដូចជា ចូលហ៊ុន ចុះកិច្ចសន្យាពាណិជ្ជកម្ម ទិញភាគហ៊ុន និងចូលរួមរាល់កិច្ចការ ឬសហគ្រាសទាំងឡាយដែលផ្សារភ្ជាប់ទៅនឹងផលប្រយោជន៍របស់ក្រុមហ៊ុន។

៤- ចូលរួមរាល់ប្រតិបត្តិការឧស្សាហកម្ម ពាណិជ្ជកម្ម ហិរញ្ញវត្ថុ ចលនទ្រព្យ ឬ អចលនទ្រព្យ ផ្សារភ្ជាប់ដោយចំពោះ ឬមិនចំពោះ ទៅនឹងគោលបំណងរបស់ក្រុមហ៊ុន ឬអាចសម្រួលដល់សមិទ្ធផល និងការរីកចំរើននៃប្រតិបត្តិការខាងលើ ។

៥- ទទួលខុសត្រូវនិងចាត់ចែង ក្នុងការងារការពារសុវត្ថិភាព សន្តិសុខសណ្តាប់ធ្នាប់លើការងាររបស់ខ្លួន។

៦- ប្រកាន់គោលការណ៍ និងរបៀបកិច្ចការដូចគ្នានឹងអាជីវករ ។



4L

៧- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពអោយមានប្រសិទ្ធភាព និងមានការរីកចំរើន ។

៨- **កម្ពុជា រី** ទទួលពីរដ្ឋនូវសិទ្ធិនិងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

**មាត្រា ៣ .-**

**កម្ពុជា រី** ត្រូវគោរពរបបពន្ធ និងអាករ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៤ .-**

ដើមទុនដំបូងរបស់ **កម្ពុជា រី** ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលទទួលបាននូវការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ពេលអនុក្រឹត្យនេះចូលជាធរមាន **កម្ពុជា រី** ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលរដ្ឋបានប្រគល់ឱ្យ ហើយដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៥ .-**

បុគ្គលិករបស់ **កម្ពុជា រី** ត្រូវជ្រើសរើសពីចំណោមមន្ត្រីរាជការ នៃមុខងារសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាចជ្រើសរើសបុគ្គលិកខាងក្រៅបើយល់ឃើញថាចាំបាច់ ។ បុគ្គលិករបស់ **កម្ពុជា រី** ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែក អនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី២
## ការដឹកនាំ និងការគ្រប់គ្រង

**មាត្រា ៦ .-**

**កម្ពុជា រី** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | ជាប្រធាន- |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | ជាសមាជិក |
| -តំណាងក្រសួងយុត្តិធម៌ | ១រូប | ជាសមាជិក |
| -អគ្គនាយក **កម្ពុជា រី** | | ជាសមាជិក |
| -តំណាងនិយោជិតរបស **កម្ពុជា រី** | ១រូប | ជាសមាជិក |

**មាត្រា ៧ .-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសតាំងក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបម្រើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច ឬនីតិសាស្ត្រ ឬពាណិជ្ជសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់ និងអាចបន្តទៀតបាន តាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឱ្យ ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិតរបស់ **កម្ពុជា រី** ។

**មាត្រា ៨ .-**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសម្រេចក្នុងនាម **កម្ពុជា រី** ក្នុងការរៀបចំលិខិតស្នាមរាល់ឯកសារផ្សេងៗ ទាក់ទងទៅនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន ។

**ក្រុមប្រឹក្សាភិបាលមានតួនាទីជាអាទិ៍ :**

១- ផ្តល់ការយល់ព្រមលើគំរោងផែនការសហគ្រាស ដូចមានចែងក្នុងមាត្រា ១៧ នៃអនុក្រឹត្យនេះ

២- វាយតម្លៃរៀងរាល់ពេលនូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងពាតិវិធានការ ដើម្បីកែសំរួលឱ្យបានតអេស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រម លើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សេដ្ឋកិច្ច **កម្ពុជា រី** ។

៤- សម្រេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា និង អនុសញ្ញាដែល **កម្ពុជា រី** ជាភាគីហត្ថលេខី ស្របតាមល័ក្ខខ័ណ្ឌនិងបែបបទ ដូចមានចែងក្នុងបទបញ្ជាជាធរមាន ។

៦- សម្រេចបង្កើត បើក ឬបិទភ្នាក់ងារ សាខា ឬការិយាល័យរបស់ **កម្ពុជា រី** តាមការវិនិច្ឆ័យរបស់ខ្លួន។

៧- ផ្តល់ការយល់ព្រមលើសំណើ នៃការបណ្តាក់ទុនសម្រាប់មូលនិធិទំនេររបស់ក្រុមហ៊ុន ។

៨- ផ្តល់ការយល់ព្រមលើសំណើទិញ ផ្លាស់ប្តូរ ឬលក់ចលនទ្រព្យ និងអចលនទ្រព្យ ព្រមទាំងរាល់សំណើខ្ចីដោយមានវត្ថុបញ្ចាំ ឬដោយគ្មានវត្ថុបញ្ចាំ ឬការធានាផ្សេងៗទៀត លើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។

**មាត្រា ៩ .-**

ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំគ្រប់ពេលវេលា អាស្រ័យដោយអត្ថប្រយោជន៍របស់សហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់សមាជិក ដែលមានចំនួនបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច ១ ដង ក្នុងរយៈពេល ៣ ខែ ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកមានអាយុច្រើនជាងគេ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលដែលមានវត្តមានក្នុងអង្គប្រជុំ ចាត់ចែងបោះឆ្នោតជ្រើសរើសប្រធានអង្គប្រជុំ ។

ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតនៅក្នុងគ្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃអង្គប្រជុំព្រមទាំងឯកសារ ដែលទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច ១០ ថ្ងៃមុនពេលបើកអង្គប្រជុំ ។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកយ៉ាងតិចបីនាក់ ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ ថ្ងៃក្រោយ ដើម្បីពិភាក្សាឡើងវិញ លើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។ សេចក្ដីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះណាតែមានការអនុម័ត ដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា ១០ .-**

សេចក្ដីសម្រេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ និងស្ថាប័នដទៃទៀត ដែលមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ក្នុងរវាង ១៥ ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាល នាសម័យប្រជុំលើកក្រោយ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រជាប្រូវហែរ និងមានអត្តលេខចំណាំត្រឹមត្រូវ ។ កំណត់ហេតុដើមត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ដែលវត្តមាន និងលេខាធិការជ្រើសរើសដោយអគ្គនាយក ។

**មាត្រា ១១ .-**

អគ្គនាយកមានភារកិច្ចគ្រប់គ្រងការងារនៃ **កម្ពុជា រី** ជាប្រក្រតី និងត្រូវបានតែងតាំងសម្រាប់អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ តំណែងនេះអាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបាន តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១២ .**

ក្រុមប្រឹក្សាភិបាលណែនាំ និងប្រគល់ជូនអគ្គនាយកនូវអំណាចចាំបាច់ សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមាន លទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំសហគ្រាសស្របតាមច្បាប់ តំណាងឱ្យ **កម្ពុជា រី** និងទទួលខុសត្រូវចំពោះមុខតុលាការ។

ក្នុងក្របខ័ណ្ឌនេះ អគ្គនាយកមានភារកិច្ច :

១- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ សម្រេច និងចាត់ចែងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល តាមតំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **កម្ពុជា រី** ។

២- ទទួលបន្ទុកដឹកនាំ **កម្ពុជា រី** ផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម សេវាកម្ម និង ហិរញ្ញវត្ថុ ។

៣- មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណាង ឬបញ្ឈប់ការងារ និងមានសិទ្ធិត្រួតត្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **កម្ពុជា រី** ដោយគោរពតាមលក្ខន្តិកៈបុគ្គលិក ឬច្បាប់ជាធរមាន និងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

៤- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៥- តំណាងឱ្យ **កម្ពុជា រី** នឹងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់តវ៉ា ការពារក្តីឱ្យ **កម្ពុជា រី** និងប្តឹងជំទាស់ផ្សេងៗ ។

**មាត្រា ១៣ .-**

លាភការក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៤ .-**

ការចុះនិងការអនុវត្តកិច្ចសន្យាដោយ **កម្ពុជា រី** ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន និងច្បាប់ជាធរមាន ។

## ជំពូកទី៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៥ .-**

**កម្ពុជា រី** កាន់កាប់គណនេយ្យរបស់ខ្លួន ស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំដដែល។

របាយការណ៍ហិរញ្ញវត្ថុនិងគណនីគ្រប់គ្រង ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលមុនថ្ងៃទី ៣១ ខែមិនា នៃការិយបរិច្ឆេទបន្ទាប់ ។



41

របាយការណ៍ហិរញ្ញវត្ថុនិងគណនីគ្រប់គ្រង ត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃ ព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃ សហគ្រាសសាធារណៈ ។

**មាត្រា ១៦ .-**

រៀងរាល់ឆ្នាំ មុនថ្ងៃទី ០១ ខែតុលា ក្រុមប្រឹក្សាភិបាល ត្រូវផ្តល់ការយល់ព្រមលើគម្រោងផែនការ ប្រចាំឆ្នាំរបស់ **កម្ពុជា រី** តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគម្រោងនេះ ដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧ .-**

ធនធាននៃ **កម្ពុជា រី** ជាអាទិ៍មាន :

-ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យ (តុល្យការដំបូងនៅពេលបង្កើត)

-ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យបន្ថែម

-ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពរបស់ **កម្ពុជា រី**

-ប្រាក់បានមកពីការលក់ ឬជួលចលនវត្ថុ និងអចលនវត្ថុ របស **កម្ពុជា រី**

-ប្រាក់បានមកពីការខ្ចីបុល និងប្រាក់អំណោយផ្សេងៗ ។

**មាត្រា ១៨ .-**

ចំណាយនៃ **កម្ពុជា រី** រួមមាន :

-ចំណាយប្រក្រតីសម្រាប់ដំណើរការ

-ចំណាយវិនិយោគ

-ចំណាយសងបំណុល

-ចំណាយផ្សេងៗ ។

**មាត្រា ១៩ .-**

**កម្ពុជា រី** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សម្រាប់ តំរូវការរបស់ខ្លួន ។

**មាត្រា ២០ .-**

**កម្ពុជា រ៉ែ** ត្រូវបង់ប្រាក់ចំណេញពិតប្រចាំឆ្នាំ ចូលថវិការដ្ឋចំនួន ៧០% ហើយរដ្ឋក៏អាចទុកប្រាក់ចំណេញនេះទាំងអស់ឱ្យសហគ្រាសផងដែរ ក្នុងករណីដែលរដ្ឋពិនិត្យឃើញថា សហគ្រាសត្រូវធ្វើការអភិវឌ្ឍជាចាំបាច់ ។ ប្រាក់ចំណេញដែលនៅសល់ ក្រោយពីការបង់ចូលថវិការដ្ឋខាងលើ **កម្ពុជា រ៉ែ** មានសិទ្ធិប្រើប្រាស់ឱ្យស្របតាមលក្ខន្តិកៈរបស់សហគ្រាស ។

**មាត្រា ២១ .-**

រដ្ឋធានាចំពោះតែបំណុលណា ដែលមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២២ .-**

រយៈពេល ១៥ ថ្ងៃយ៉ាងយូរ ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **កម្ពុជា រ៉ែ** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ :

-កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល

-គម្រោងផែនការរបស់ **កម្ពុជា រ៉ែ**

-របាយការណ៍ស្តីពីសកម្មភាព របាយការណ៍ហិរញ្ញវត្ថុ និងគណនីគ្រប់គ្រងទាំងឡាយរបស់ **កម្ពុជា រ៉ែ** ។

**មាត្រា ២៣ .-**

ត្រូវបានដាក់ឱ្យនៅអម **កម្ពុជា រ៉ែ** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវបានតែងតាំង ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់ លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសំឡេងអនុម័តឡើយ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទប្បញ្ញត្តិ នៃមាត្រា ២០ ដល់មាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ២៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៥ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី-រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

**សម្តេចនាយករដ្ឋមន្ត្រី** ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤៤...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦ / អនក្រ.បក / ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ :** តែងតាំងលោក **សេង ធៀង** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើត ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ជា អៀង** ជាជំនួយការរបស់ឯកឧត្តម **សម សុគ្គា** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើប្រធាននាយកដ្ឋាន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តនអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...៤៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត /១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ**តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ០៧ រូប ដែលបានបរិច្ចាគថវិកា ជួយសាងសង់អគារសិក្សា និង វិហារឥស្លាម នៅក្នុងស្រុកត្បូងឃ្មុំ ស្រុកក្រូចឆ្មារ និងស្រុកកោះសូទិន ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោមនេះ ÷

ក - **មេដាយមាសស្ថាបនាជាតិ :**

១- លោក **ម៉ាត់ ការី** កសាងអគារសិក្សានៅភូមិសំបូរ ស្រុកត្បូងឃ្មុំ
ថវិកា ១២.៣០០ USD

២- លោក **ណាសៀត ពិន ខឡេត** កសាងអគារសិក្សានៅភូមិជំនីក ស្រុកក្រូចឆ្មារ
ថវិកា ១០.០៥០ USD

៣- លោក **ស៊ីម សុខត្រី** កសាងអគារសិក្សានៅភូមិជំនីក ស្រុកក្រូចឆ្មារ
ថវិកា ១០.១៤០ USD

៤- លោក **លី ម៉ាត** កសាងវិហារនៅភូមិតានង់ទី ១១ ស្រុកកោះសូទិន
ថវិកា ១១.០៣៥ USD

៥- លោក **ហាសាន់ ពិនអ៊ីព្រាហ៊ីម** កសាងវិហារនៅភូមិតានង់ទី ១១ ស្រុកកោះសូទិន
ថវិកា ១០.០២០ USD

៦- លោក **ស៊ាហារី ពិនអ៊ីស្មាឯល** កសាងវិហារនៅភូមិតានង់ទី ១១ ស្រុកកោះសូទិន ថវិកា ១០.០៥០ USD

ខ- **មេដាយសេរីវឌ្ឍស្ថាបនាជាតិ**

- លោក **លី អេស** កសាងវិហារនៅភូមិតានង់ទី ១១ ស្រុកកោះសូទិន ថវិកា ២.០៦៧ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

រាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៤១៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត /១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តសៀមរាប

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម **វណ្ណ សុផាណ្ណា** ទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា និង លោកជំទាវ **ម៉ារ គឹមសាយ** ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនយ៉ាងច្រើនដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ និង ស្តារហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងស្រុកបន្ទាយស្រី និងមន្ទីរកសិកម្ម - រុក្ខាប្រមាញ់ និង នេសាទ ខេត្តសៀមរាប សរុបទឹកប្រាក់ចំនួន ១៦២.៦៥៣ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកប្រតិបត្តិនៃសហគមន៍អាស៊ី ខ្មែរ

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ដែលបានជួយកសាងអាគារសិក្សាចំនួន ០២ ខ្នង នៅសាលាបឋមសិក្សាក្បាលដំរី ឃុំគោកព្រេច ស្រុកគីរីវង្ស និង សាលាបឋមសិក្សាត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន ៤៦.១៧៣ USD ដូចមានខាងក្រោម ÷

១- ប្រជាជនជប៉ុន តាមរយៈកម្មវិធី **KUSANONE** នៃស្ថានទូតជប៉ុន ប្រចាំកម្ពុជា

២- សហគមន៍មិត្តភាព អាស៊ី ខ្មែរ និង ជប៉ុន ( **KAFS - JAFS** )

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...០.៧...សសរ

## សេចក្ដីសំរេច

## ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំលើកទី ២ នៃនាយករដ្ឋមន្ត្រីទាំង ៣ វៀតណាម - កម្ពុជា - ឡាវ ស្ដីពីការអភិវឌ្ឍន៍ត្រីកោណ ចាប់ពីថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០២ រហូតដល់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៨...សសរ...

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារ ទំនប់ប្រឡាយ នៅតំបន់ព្រំដែនកម្ពុជា_វៀតណាម_ឡាវ_ថៃ

ᨓᨔᨕ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

-យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ប្រឡាយ នៅតំបន់ព្រំដែនកម្ពុជា វៀតណាម – ឡាវ – ថៃដែលមានសមាសភាពដូចតទៅ :-

១-ឯកឧត្តម **ម៉ុន ហ៊ាន** អគ្គនាយកកិច្ចការបច្ចេកទេស នៃក្រសួងធនធានទឹកនិងឧតុនិយម ប្រធាន

២-លោក ហួន សាវ៉ាន អគ្គនាយករង នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាតំណាងគណៈកម្មាធិការចំរុះកិច្ចការព្រំដែន អនុប្រធាន

៣-លោក កែវ ភក្តី អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុលនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤-លោក គីង ភារុទ្ធី នាយក នៃនាយកដ្ឋានផ្លូវទឹក ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៥-លោក ហួយ គីមឡុន: ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

៦-លោក ពេជ ឌុន ប្រធាននាយកដ្ឋានគំរោង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក

៧-លោក មាស សុផល អនុប្រធាននាយកដ្ឋានការពារអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន សមាជិក

៨-លោក គិត សេង អនុប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៩-លោក នូ នីម នាយអគ្គលេខាធិការដ្ឋានសាលាខេត្តកណ្តាល សមាជិក

១០-លោក ស៊ុយ ស៊ីថុន ប្រធានការិយាល័យធារាសាស្ត្រ នាយកដ្ឋានកសិកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**ប្រការ២ :** គណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ប្រឡាយតំបន់ព្រំដែនកម្ពុជា-វៀតណាម ឡាវ-ថៃមានភារកិច្ចដូចតទៅ :-

ក-ចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែង នូវបញ្ហាប្រឈមមុខបច្ចុប្បន្ន អំពីផលប៉ះពាល់ដល់បរិស្ថានសង្គម ធម្មជាតិ នៅតំបន់ព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កឡើងអំពីការលើកទំនប់ និងជីកប្រឡាយរបស់ភាគីវៀតណាម ដោយផ្អែកលើ :-

១-កិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈព្រំដែន រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ២០-៧-១៩៨៣ ត្រង់ប្រការ៨ ចំណុច គ

២-សេចក្តីប្រកាសពតិមានរួមរបស់រដ្ឋាភិបាលទាំងពីរកម្ពុជា-វៀតណាម ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៥ និងបណ្តាឯកសារដទៃទៀតដែលពាក់ព័ន្ធ ។

ខ-ពិភាក្សាជាមួយគណៈកម្មាធិការបច្ចេកទេសវៀតណាម ដោយអោយភាគីនេះ បញ្ជាក់អោយបានច្បាស់លាស់នូវផលប៉ះពាល់ ដូចមានចែងក្នុងចំណុច ក ខាងលើ និងរិះរកវិធានការផ្សេងៗដែលខ្លួនត្រូវប្រកាន់យក ដើម្បីបញ្ចៀសនូវផលប៉ះពាល់ដល់បរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់ព្រំដែននៃប្រទេសទាំងពីរ ។

គ-ធ្វើរបាយការណ៍សរុបអំពីលទ្ធផលការងារដាក់ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេច ។

ឃ-ធ្វើការងារដទៃទៀតដែលមានអត្ថន័យ និងខ្លឹមសារប្រហាក់ប្រហែលគ្នានេះ តាមការប្រគល់ភារកិច្ចដោយប្រមុខរាជរដ្ឋាភិបាល ។

ប្រការ៣ : សមាជិកគណៈកម្មាធិការចំរុះអចិន្ត្រៃយ៍ សំរបសំរួលការងារទំនប់ប្រឡាយ នៅតំបន់ព្រំដែនកម្ពុជា វៀតណាម ឡាវ ថៃ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ៤ : គណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ ប្រឡាយ នៅតំបន់ព្រំដែនកម្ពុជា វៀតណាម ឡាវ ថៃ មានទីស្នាក់ការនៅក្រសួងធនធានទឹក និងឧតុនិយម និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម ។

ប្រការ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០១ សរណន

# សារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា

ដោយសង្កេតឃើញថា អ្នកដឹកនាំតៃវ៉ាន់មួយចំនួន បានមកប្រទេសកម្ពុជា ដើម្បីជួបសំណេះសំណាល ជាមួយតំណាងស្ថាប័នខ្លះៗ ក្នុងរូបភាពឯកជន និង តាមពត៌មានបានអោយដឹងថា មានគំរោងការអោយ វិស័យឯកជនអញ្ជើញអ្នកដឹកនាំកម្ពុជា ទៅទស្សនកិច្ចនៅតៃវ៉ាន់ តាមរូបភាពផ្សេងៗ ដូចជា ទៅសំរាកលំហែ កាយជាដើម រាជរដ្ឋាភិបាលកម្ពុជាសូមបញ្ជាក់ជាថ្មីម្តងទៀត នូវជំហរឥតងាករេរបស់ខ្លួនក្នុងការគាំទ្រ "គោល នយោបាយចិនមួយ " ហើយបដិសេធទាំងស្រុង នូវរាល់សកម្មភាពដែលមានបំណងបំបែកបំបាក់ប្រទេសចិន ជាពីរ ដោយផ្តាច់តៃវ៉ាន់ពីមហាប្រទេសចិន ។

រាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំដល់មន្ត្រីរាជការ និងសមាជិក-សមាជិកានៃរាជរដ្ឋាភិបាល កម្ពុជា អោយជៀសវាងធ្វើទំនាក់ទំនងតាមរូបភាពជាផ្លូវការ ជាមួយថ្នាក់ដឹកនាំតៃវ៉ាន់ ដែលជាការដើរផ្ទុយ នឹងជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជា បដិសេធផ្តល់ទិដ្ឋាការផ្លូវការនិងទិដ្ឋាការការទូត ដល់ជនជាតិ ចិនតៃវ៉ាន់នៅគ្រប់ច្រកចេញ-ចូលអន្តរជាតិ នៅក្នុងប្រទេសកម្ពុជា ។

រាជរដ្ឋាភិបាលនិងប្រជាពលរដ្ឋកម្ពុជា ជានិច្ចកាលបន្តពង្រឹងពង្រីកទំនាក់ទំនងមិត្តភាពជាប្រពៃណី និង កិច្ចសហប្រតិបត្តិការល្អ ជាមួយរដ្ឋាភិបាលនិងប្រជាពលរដ្ឋចិន អោយកាន់តែរឹងមាំថែមទៀត ដើម្បីជាផល ប្រយោជន៍រួមនៃប្រទេសទាំងពីរ ។

ក្រោយពីទទួលបានការណែនាំនេះ មន្ត្រីរាជការ និងសមាជិក-សមាជិកានៃរាជរដ្ឋាភិបាល ត្រូវអនុវត្ត តាមសារាចរណែនាំនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ : ០៧០ សហវ.ប្រក

# ប្រកាស

**ស្តីពី**

**ការចាត់តាំងមន្ត្រីរាជការជាជំនួយការ**

**ក្នុងកម្មវិធីពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.៩៤.០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥/អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ លើកម្មវិធីពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០១
- បានឃើញការប្រកាសបើកជាផ្លូវការនូវគំរោងពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយសហគមផ្តល់ជំនួយ កាលពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០១
- បានឃើញតំរូវការចាំបាច់របស់កម្មវិធីពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**ប្រការ១:** ចាត់តាំងមន្ត្រីរាជការដែលមានរាយនាមដូចខាងក្រោម ជាជំនួយការទៅតាមផ្នែកនីមួយៗ នៃកម្មវិធីពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចខាងក្រោមៈ

*ក. ជំនួយការខាងផ្នែកថវិកានីយកម្ម និង ហិរញ្ញកិច្ច*

១. លោក **អៀង ស៊ុនលី** អនុប្រធានទី១ នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច
២. លោក **លីវ ប៊ុនហៃ** អនុប្រធាន នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច
៣. លោក **ហុិញ ឫទ្ធីពល** មន្ត្រីនាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច
៤. លោក **ពៅ បញ្ញា** ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
៥. លោក **ទេព ភិយ្យោរិទ្ធ** មន្ត្រីអង្គភាពផែនការនីយកម្ម និង តាមដានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ខ. ជំនួយការខាងផ្នែករតនាគារជាតិ*

១. លោក **ហ៊ីវ សុវណ្ណ** អនុប្រធានទី១ រតនាគារជាតិ
២. លោក **ឈឹម សារ៉េត** អនុប្រធានរតនាគារជាតិ
៣. លោក **ឈាន ហៀង** ប្រធានការិយាល័យគណនេយ្យនៃរតនាគារជាតិ
៤. លោក **ប៉ែន ចាន់លី** ប្រធានការិយាល័យទំនាក់ទំនង និង សិក្សាស្រាវជ្រាវនៃរតនាគារជាតិ
៥. លោក **ឡាយ សុខឃៀង** មន្ត្រីអង្គភាពផែនការនីយកម្ម និង តាមដានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*គ. ជំនួយការខាងផ្នែកពន្ធដារ*

១. លោក **មុត ណុច** មន្ត្រីការិយាល័យប្រមូលពន្ធតាមរបបពិត
២. លោក **ហៀន សុខល់** មន្ត្រីអង្គភាពនយោបាយសារពើពន្ធ
៣. លោក **អ៊ុក សំបូណា** មន្ត្រីអង្គភាពនយោបាយសារពើពន្ធ
៤. លោក **អៀម ង៉ា** មន្ត្រីអង្គភាពផែនការនីយកម្ម និង តាមដានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
៥. លោក **ជា ដារា** ប្រធានការិយាល័យរដ្ឋបាលនៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ឃ. ជំនួយការខាងផ្នែកគយ និង រដ្ឋាករ*

១. លោក **យុត វរៈទិម** មន្ត្រីគយ ការិយាល័យត្រួតពិនិត្យ
២. លោក **យូ ហេង** មន្ត្រីគយ ការិយាល័យប្រឆាំងនឹងការរត់ពន្ធ
៣. លោក **ញ៉ែត សម្បត្តិ** មន្ត្រីគយ ព្រលានយន្តហោះពោធិ៍ចិនតុង
៤. លោក **តេក សៀកឯន** មន្ត្រីគយអាស៊ាន
៥. លោក **អិម វិបុល** មន្ត្រីអង្គភាពផែនការនីយកម្ម និង តាមដានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ប្រការ២:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១ ខាងលើត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២

**គាត ឈន់**

**ចំលងជូន:**

- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី
- អគ្គលេខាធិការ
- ទីចាត់ការគយ និង រដ្ឋាករ
- នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច
- នាយកដ្ឋានពន្ធដារ
- ធនាគារជាតិ
- នាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធ
- សាមីខ្លួន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៧៤ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២

# ប្រកាសបន្ថែម
# លើ
# ប្រកាសលេខ ៨៧៥-៨៧៦-៨៧៧ និង ៨៧៨ សហវ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពី ការដាក់អាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនភ្នាក់ងារកាមិនក្ស ស្ថិតក្នុងភាពផុតសុពលភាព

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនឹងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨
- ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ២០០១ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញការចាំបាច់នៃការងារគ្រប់គ្រង

## សម្រេច

**ប្រការ ១ :**

ដើម្បីធានានិរន្តរភាពនៃអាជីវកម្មរបស់ក្រុមហ៊ុនភ្នាក់ងារទាំងបួន : Indochine Insuranec Union , Forte Trading Private Ltd , Asia Insurance (Cambodia ) Ltd , និង Pana Trading Cambodia ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានទុករយៈពេល បី (៣) ខែ ដោយគិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០២ តទៅដើម្បីឱ្យក្រុមហ៊ុនភ្នាក់ងារទាំងអស់មានលទ្ធភាព គ្រប់គ្រាន់សំរាប់រៀបចំ និង ដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណថ្មីមកក្រសួង ។

**ប្រការ ២ :**

ក្នុងរយៈពេល បី (៣) ខែ ដែលបានទុកបន្ថែមឱ្យនេះ ក្រុមហ៊ុនភ្នាក់ងារទាំងអស់ ត្រូវអនុវត្តកាតព្វកិច្ចជាភ្នាក់ងាររបស់កាមិនកូ ដូចពេលមុនដដែល ។

**ប្រការ ៣ :**

ប្រកាសនេះមានប្រសិទ្ធភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣៤ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០០២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត-ក្រុង

## សម្រេច

**ប្រការ១.-** អាករសម្រាប់ការបំភ្លឺសាធារណៈ ត្រូវប្រមូលចំនួន ៣ ភាគរយ លើតម្លៃសុរាមេរ័យ និងបារី ដែលលក់ក្នុងមណ្ឌលដែនដីខេត្ត-ក្រុងនីមួយៗ ។

ត្រូវជាប់អាករនេះផងដែរ ចំពោះការដកយក សុរាមេរ័យ និងបារី សម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់បុគ្គលជាប់អាករ របស់បុគ្គលិក ឬសម្រាប់តតិយជន។

**ប្រការ២.-** ត្រូវបានចាត់ជា សុរាមេរ័យ និងបារី ដែលត្រូវជាប់អាករតាមប្រការ១ ខាងលើរួមមាន :

- ស្រាបៀរ
- ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរដែលមានបន្ថែមជាតិសុរា
- ស្រាវែមុត និង ស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតផ្សំពីរុក្ខជាតិ និង សារជាតិក្រអូប
- ភេសជ្ជៈមេរ័យផ្សេងទៀត លើកលែងតែទឹកត្នោតជូរ និងស្រាស
- អាល់កុលអេទីលិកសុទ្ធដែលមានកំរិតជាតិសុរាក្នុងឯកតាចំណុះពី ៨០% នៃចំណុះ ឬលើសពីនេះ និងអាល់កុលអេទីលិក ហើយនិងភេសជ្ជៈមានជាតិសុរាដែលបាត់បង់កំរិតសុរាដើមរបស់វា
- អាល់កុលអេទីលិកបាត់បង់ធាតុសុទ្ធដែលមានកំរិតជាតិសុរាក្នុងឯកតាចំណុះ ៨០% នៃចំណុះ និង ភេសជ្ជៈ មានជាតិសុរា ភេសជ្ជៈស្រវឹងផ្សេងៗទៀត ការរៀបចំកែច្នៃសុរាផ្សំក្នុងប្រភេទដែលប្រើសម្រាប់ផលិតភេសជ្ជៈ
- បារី បារីស៊ីហ្គា គ្រប់ប្រភេទ ។

**ប្រការ៣.-** អាករនេះត្រូវកំណត់នៅគ្រប់ដំណាក់កាលផ្គត់ផ្គង់ និងត្រូវអនុវត្តលើតម្លៃផ្គត់ផ្គង់ផលិតផលជាប់អាករ រួមបញ្ចូលទាំងពន្ធអាករនានា លើកលែងតែអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង និងអាករលើតម្លៃបន្ថែមចំពោះបុគ្គលជាប់អាករតាមរបបពិត ឬអាករលើផលរបរចំពោះបុគ្គលជាប់អាករតាមរបបម៉ៅការ ។

អាករសម្រាប់បំភ្លឺសាធារណៈនេះ ត្រូវដល់កំណត់ និងត្រូវបង់នៅពេលផ្គត់ផ្គង់ ។

វិធានកំណត់ពេលផ្គត់ផ្គង់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិចែងសម្រាប់អាករលើតម្លៃបន្ថែម និងអាករលើផលរបរ ។

**ប្រការ៤.-** បុគ្គលដែលធ្វើការផ្គត់ផ្គង់ សុរាមេរ័យ និងបារី គឺជាបុគ្គលជាប់អាករសម្រាប់បំភ្លឺសាធារណៈ និងត្រូវទទួលខុសត្រូវបង់ប្រាក់អាករនេះ។

ដើម្បីគណនាប្រាក់អាករត្រូវបង់ បុគ្គលជាប់អាករត្រូវធ្វើការបែងចែកឱ្យបានរវាងផលរបរដែលបានមកពីការផ្គត់ផ្គង់សុរាមេរ័យ និងបារី ជាប់អាករ និងផលរបរបានមកពីការផ្គត់ផ្គង់ទំនិញ ឬសេវាដ៏ទៃទៀត ។

ក្នុងករណីដែលបុគ្គលជាប់អាករតាមរបបម៉ៅការពុំអាចធ្វើការបែងចែកផលរបរបាន មន្ត្រីពន្ធត្រូវពិភាក្សាជាមួយបុគ្គលជាប់អាករ ដើម្បីកំណត់សមាមាត្រនៃផលរបរបានមកពីការផ្គត់ផ្គង់ សុរាមេរ័យ និងបារី ជាប់អាករ ។ សមាមាត្រនេះត្រូវបានពិនិត្យ និងសម្រេច ដោយប្រធានសាខាពន្ធដារខេត្ត-ក្រុង ។

**ប្រការ៥.-** បុគ្គលជាប់អាករតាមរបបពិត ត្រូវដាក់លិខិតប្រចាំខែ យ៉ាងយឺតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ហើយត្រូវបង់ប្រាក់អាករនេះទៅតាមចំនួនដែលបានប្រកាស នៅពេលដាក់លិខិតប្រកាសនោះ ។

បុគ្គលជាប់អាករតាមរបបម៉ៅការ ត្រូវបង់ប្រាក់អាករនេះជារៀងរាល់ខែ យ៉ាងយឺតត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ ។

បទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ដែលចែងក្នុងច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រូវយកមកអនុវត្តចំពោះអាករសម្រាប់បំភ្លឺសាធារណៈនេះ ។

**ប្រការ៦.-** អង្គភាពមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈនេះត្រូវបានកំណត់ដូចខាងក្រោម :

- ការិយាល័យគ្រប់គ្រងប្រមូលពន្ធតាមរបបពិត មានភារកិច្ចប្រមូលអាករនេះ ចំពោះបុគ្គលជាប់អាករតាមរបបពិត ។

- សាខាពន្ធដារខេត្ត-ក្រុង មានភារកិច្ចប្រមូលអាករនេះ ចំពោះបុគ្គលជាប់អាករតាមរបបម៉ៅការនៅក្នុង មណ្ឌលដែនដីខេត្ត-ក្រុងរបស់ខ្លួន ។
- ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរាជធានីភ្នំពេញ ក្រុងប៉ៃលិន ក្រុងកែប អភិបាលគ្រប់ខេត្ត-ក្រុង មានសិទ្ធិតាមដានជំរុញនូវការប្រមូលចំណូលទាំងនោះ ។

**ប្រការ៧.-** ប្រាក់ចំណូលបានមកពីការប្រមូលអាករនេះ ត្រូវបានជាប្រយោជន៍ថវិកាខេត្ត-ក្រុង ទុកសម្រាប់ចំណាយឱ្យការបំភ្លឺសាធារណៈ ។

**ប្រការ៨.-** អគ្គនាយករដ្ឋបាល នាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរាជធានីភ្នំពេញ ក្រុងប៉ៃលិន ក្រុងកែប អភិបាលគ្រប់ខេត្ត-ក្រុង ប្រធាននាយកដ្ឋានពន្ធដារ និង ប្រធាននាយកដ្ឋាននានាចំណុះឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាព ។

**ប្រការ៩.-** ប្រកាសនេះមានប្រសិទ្ធិភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សហរដ្ឋមន្ត្រី
ក្រសួងមហាផ្ទៃ

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :
- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៨ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៧៦ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## បទប្បញ្ញត្តិដែលត្រូវអនុវត្តចំពោះ ភ្នាក់ងារធានារ៉ាប់រង និង ជើងសារធានារ៉ាប់រង

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៨៦ ចុះ ថ្ងៃទី ២៥ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនឹងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញការចាំបាច់នៃការងារគ្រប់គ្រង ។

## សំរេច

**ប្រការ ១.-**

ភ្នាក់ងារធានារ៉ាប់រង មិនអាចរៀបចំ ឬកាន់កាប់ដោយប្រើសិទ្ធិរៀបចំកិច្ចសន្យាធានារ៉ាប់រង ក្នុងនាមជាភ្នាក់ងាររបស់ក្រុមហ៊ុនធានារ៉ាប់រងណាមួយទេ ប្រសិនបើភ្នាក់ងារធានារ៉ាប់រងមិនបានធ្វើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយក្រុមហ៊ុនធានារ៉ាប់រងនោះ និងសាមីក្រុមហ៊ុនធានារ៉ាប់រងមិនបានអនុញ្ញាត ឱ្យភ្នាក់ងារធានារ៉ាប់រង រៀបចំ ÷

ក- កិច្ចសន្យាធានារ៉ាប់រងនោះ ,

ខ- កិច្ចសន្យាធានារ៉ាប់រងណាមួយ ,ឬ

គ- ក្រុមនៃកិច្ចសន្យាធានារ៉ាប់រង ដែលក្នុងនោះរួមមានកិច្ចសន្យាធានារ៉ាប់រងនោះ , ក្នុងនាមជាភ្នាក់ងារធានារ៉ាប់រងរបស់ក្រុមហ៊ុនខ្លួនទេ ។

**ប្រការ ២.-**

ក្រុមហ៊ុនធានារ៉ាប់រង ដែលមានអាជ្ញាប័ណ្ណ ឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា មិនអាចបង្ក ឬ អនុញ្ញាតឱ្យភ្នាក់ងារធានារ៉ាប់រងណាមួយរៀបចំឬកាន់កាប់ដោយប្រើសិទ្ធិរៀបចំកិច្ចសន្យាធានារ៉ាប់រង ក្នុងនាមជាភ្នាក់ងាររបស់ក្រុមហ៊ុនខ្លួនដោយមិនមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងសាមីក្រុមហ៊ុនជាមួយនឹងភ្នាក់ងារនោះ និងសាមីភ្នាក់ងារធានារ៉ាប់រង មិនបានទទួលការអនុញ្ញាត ឱ្យរៀបចំ ÷

ក- កិច្ចសន្យាធានារ៉ាប់រងនោះ ,

ខ- កិច្ចសន្យាធានារ៉ាប់រងណាមួយ ឬ

គ- ក្រុមនៃកិច្ចសន្យាធានារ៉ាប់រង ដែលក្នុងនោះ រួមមានកិច្ចសន្យាធានារ៉ាប់រង នោះ , ក្នុងនាមជាភ្នាក់ងាររបស់ ក្រុមហ៊ុនខ្លួនទេ ។

**ប្រការ ៣.-**

ខ្លឹមសារនៃប្រការ ( ១ ) និងប្រការ ( ២ ) ខាងលើមិនអនុវត្តចំពោះនិយោជិតរបស់ក្រុមហ៊ុនធានារ៉ាប់រងក្នុងការបំរើសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន និង ដែលសាមីក្រុមហ៊ុនបានប្រគល់សិទ្ធិ ឱ្យនោះទេ ។

**ប្រការ ៤.-** ភ្នាក់ងារធានារ៉ាប់រងទាំងអស់ ពេលបានទទួលការយល់ព្រមឱ្យធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ ហើយដែលបានធ្វើជាភ្នាក់ងាររបស់ក្រុមហ៊ុនធានារ៉ាប់រង ដទៃទៀតនោះ ត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីការអនុវត្តន៍របស់ខ្លួន ។ ទន្ទឹម នឹងនោះត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ នូវច្បាប់ថតចម្លងកិច្ចព្រមព្រៀងរវាង សាមីភ្នាក់ងារជាមួយក្រុមហ៊ុនធានារ៉ាប់រង ។

ប្រការ ៥.-

ភ្នាក់ងារធានារ៉ាប់រងទាំងអស់ដែលបានទទួលអាជ្ញាប័ណ្ណឱ្យធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា មិនអាចធ្វើជាភ្នាក់ងារ ឱ្យក្រុមហ៊ុនធានារ៉ាប់រង ដែលចុះបញ្ជីនៅក្រៅព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

ប្រការ ៦.-

ជើងសាធានារ៉ាប់រង ដែលមានអាជ្ញាប័ណ្ណ ឱ្យ ធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកមួយ ឬច្រើនដើម្បីធ្វើជាក្រុមហ៊ុនមេសំរាប់ចេញវិញ្ញាបនប័ត្រធានារ៉ាប់រងចំពោះអតិថិជនរបស់ខ្លួន ។

ទន្ទឹមនឹងនោះជើងសាធានារ៉ាប់រងទាំងអស់ត្រូវ អនុវត្តកាតព្វកិច្ចផ្ទេរសំពៀតប័ណ្ណសន្យារ៉ាប់រងដែលសាមីជើងសាធានារ៉ាប់រង បានទទួលធ្វើជាអន្តរការីនោះ ចំនួន ២០% ជូនរដ្ឋ ។

ជើងសាធានារ៉ាប់រងទាំងអស់ត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវច្បាប់ថតចម្លងកិច្ចព្រមព្រៀងរវាងសាមីជើងសាធានារ៉ាប់រង ជាមួយក្រុមហ៊ុនធានារ៉ាប់រងមេ និង ច្បាប់ថតចម្លងកិច្ចព្រមព្រៀង រវាងសាមីជើងសាធានារ៉ាប់រងជាមួយទីផ្សារក្រៅប្រទេសកម្ពុជា ។

ប្រការ ៧.-

ការបង់នូវចំនួនទឹកប្រាក់ណាមួយទៅឱ្យភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រងដោយអ្នកត្រូវបានធានារ៉ាប់រង ឬ តំណាងរបស់អ្នកត្រូវបានធានារ៉ាប់រង អនុលោមតាមកិច្ចសន្យាធានារ៉ាប់រងដែលបានរៀបចំ ឬ ធ្វើឡើងដោយភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រងទោះជាការបង់បុព្វលាភរ៉ាប់រង ឬ ជាការបង់ប្រាក់អ្វីផ្សេងក៏ដោយ គឺត្រូវរួចផុតពីការទទួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រងចំពោះទឹកប្រាក់នៃការបង់នោះ ។ ការបង់ប្រាក់នោះចាត់ទុកជាការបង់ប្រាក់ជូនក្រុមហ៊ុនធានារ៉ាប់រង ដោយអ្នកត្រូវបានធានារ៉ាប់រង ដែរ ។

ប្រការ ៨.-

ការបង់ប្រាក់ដោយក្រុមហ៊ុនធានារ៉ាប់រង ទៅឱ្យភ្នាក់ងារ / ជើងសាធានារ៉ាប់រង នូវចំនួនទឹកប្រាក់ត្រូវបង់ជូនអ្នកត្រូវបានធានារ៉ាប់រង ទោះជាក្រោមរូបភាពជាទឹកប្រាក់ធ្វើសំណង ជាបុព្វលាភរ៉ាប់រងបង្វិលជូនវិញ ឬជាទឹកប្រាក់អ្វីផ្សេងក៏ដោយ ដែលទាក់ទងនឹងកិច្ចសន្យាធានារ៉ាប់រង មិនត្រូវរួចផុតពីការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រង ចំពោះអ្នកត្រូវបានធានារ៉ាប់រង នូវទឹកប្រាក់ដែលត្រូវបង់នោះឡើយ ។

ប្រការ ៩.-

កិច្ចព្រមព្រៀងទាំងឡាយណាដែលអះអាងផ្ទុយពីប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ១០.-

ប្រការ ៩ នៃប្រកាសនេះមិនអាចទុកជានិរាករណ៍នូវកិច្ចព្រមព្រៀងរវាងភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រង និង អ្នកត្រូវបានធានារ៉ាប់រងដែលអនុញ្ញាតឱ្យភ្នាក់ងារ / ជើងសាជួយសំរួលទូទាត់នូវបុព្វលាភរ៉ាប់រងជូនក្រុមហ៊ុនធានារ៉ាប់រង ជំនួសខ្លួននោះឡើយ ។

ប្រការ ១១.-

ភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រងទាំងឡាយមិនអាចផ្តល់ជូននូវកិច្ចសន្យាធានារ៉ាប់រង ឬសំណើ ឱ្យចុះកិច្ចសន្យាធានារ៉ាប់រងដល់ជនណាម្នាក់ដោយមិនបានប្រាប់ឱ្យគេដឹងអំពី÷

ក- ឈ្មោះរបស់ក្រុមហ៊ុនធានារ៉ាប់រង .

ខ- ទំនាក់ទំនងរបស់ខ្លួនជាមួយក្រុមហ៊ុនធានារ៉ាប់រង ,និង

គ- បុព្វលាភរ៉ាប់រងកំណត់ដោយក្រុមហ៊ុនធានារ៉ាប់រងនោះឡើយ ។

ប្រការ ១២.-

ភ្នាក់ងារធានារ៉ាប់រង / ជើងសាធានារ៉ាប់រងទាំងឡាយមិនអាចរៀបចំប័ណ្ណសន្យារ៉ាប់រងជាក្រុមសំរាប់មនុស្សពីរនាក់ ឬច្រើននាក់បានទេ កាលបើជនដែលត្រូវបានធានារ៉ាប់រងដោយប័ណ្ណសន្យារ៉ាប់រងជាក្រុមណាម្នាក់ដែលទទួលខុសត្រូវបង់បុព្វលាភរ៉ាប់រង មិនបានបញ្ចេញ ឱ្យមនុស្សក្នុងក្រុមដែលត្រូវបានធានារ៉ាប់រងដោយប័ណ្ណសន្យារ៉ាប់រងជាក្រុមនោះដឹង នូវ ÷

ក- ឈ្មោះរបស់ក្រុមហ៊ុនធានារ៉ាប់រង ,

ខ- ទំនាក់ទំនងរបស់ភ្នាក់ងារ / ជើងសានោះជាមួយក្រុមហ៊ុនធានារ៉ាប់រង ,

គ- ល័ក្ខខ័ណ្ឌធានា នៃ ប័ណ្ណសន្យារ៉ាប់រងជាក្រុម , និង

ឃ- បុព្វលាភរ៉ាប់រង កំណត់ដោយក្រុមហ៊ុនធានារ៉ាប់រង ទេ ។

ប្រការ ១៣.-

ក្រុមហ៊ុនធានារ៉ាប់រងត្រូវទទួលសង ចំពោះជនដែលត្រូវបានធានារ៉ាប់រងដោយប័ណ្ណសន្យារ៉ាប់រងជាក្រុម ប្រសិនបើជនដែលត្រូវបានធានារ៉ាប់រងបានបង់បុព្វលាភរ៉ាប់រងទៅ ឱ្យម្ចាស់ប័ណ្ណសន្យារ៉ាប់រងជាក្រុមរួចហើយ ដោយឥតគិតអំពី ករណីដែលក្រុមហ៊ុនធានារ៉ាប់រង មិនបានទទួលបុព្វលាភរ៉ាប់រងពីម្ចាស់ប័ណ្ណសន្យារ៉ាប់រងជាក្រុម នោះឡើយ ។

**ប្រការ ១៤.–**

ក្រុមហ៊ុនធានារ៉ាប់រង ដែលចេញប័ណ្ណសន្យារ៉ាប់រងជាក្រុមត្រូវបង់នូវទឹកប្រាក់ដែលត្រូវបង់ក្រោមប័ណ្ណសន្យារ៉ាប់រងនេះ ទៅឱ្យជនដែលត្រូវបានធានារ៉ាប់រង ឬ ជនណាម្នាក់មានសិទ្ធិទទួលដោយផ្ទាល់ ។

**ប្រការ ១៥.–**

បទប្បញ្ញត្តិ ទាំងឡាយដែលផ្ទុយ នឹង ខ្លឹមសារនៃប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៦.–**

ប្រកាសនេះមានអានុភាព គតិយុត្តិ ចាប់ពីថ្ងៃចុះ ហត្ថលេខា ត ទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៧៧ សហវ.ថហ

# ប្រកាសណែនាំ
## ស្តីពីការអនុវត្តថវិកាខេត្ត ក្រុង ឆ្នាំ ២០០២

យោងតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីបទបញ្ញាថវិការបស់ខេត្ត ក្រុង និងប្រកាសពីលេខ ០៧១ សហវ.ថហ ដល់លេខ ០៩៤ សហវ.ថហ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូល និងការបែងចែកឥណទានថវិកាខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ ៖

### ក. អំពីចំណូល

#### ១. ចំណូលសារពើពន្ធ

ចំពោះមុខសញ្ញាចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ជាគុណប្រយោជន៍នៃថវិកាខេត្ត ក្រុងនោះ ខេត្ត ក្រុងត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយពន្ធដារអោយបានត្រឹមត្រូវរបស់មន្ត្រីពន្ធដារ និងត្រូវរួមចំណែកដាក់ចេញវិធានការជាក់ស្តែងសំរាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវអោយអ្នកជាប់ពន្ធ បង់ពន្ធបានត្រឹមត្រូវគ្រប់គ្រាន់និងទាន់ពេលវេលា ។ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ បានអនុញ្ញាតអោយខេត្ត ក្រុងប្រមូលអាករសំរាប់បំភ្លឺសាធារណៈចំនួន ៣% លើតំលៃសុរាមេរ័យ និងបារី ដែលលក់នៅក្នុងមណ្ឌលដែនដីរបស់ខ្លួន ដូច្នេះខេត្ត ក្រុងត្រូវជួយជំរុញការអនុវត្តប្រមូលអាករនេះអោយទទួលបានលទ្ធផលល្អ ។

#### ២. ចំណូលពុំមែនសារពើពន្ធ

ចំពោះចំណូលពុំមែនសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសំរាប់ថវិកាខេត្ត ក្រុងនោះខេត្ត ក្រុងត្រូវយកចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូលដែលត្រូវប្រមូលបង់ចូលរតនាគារអោយអស់ មិនត្រូវទុកចំណូលខ្លះ ដោយឡែកសំរាប់ចំណាយដោយឡែកក្រៅពីគំរោងចំណាយប្រចាំឆ្នាំឡើយ ។ ចំពោះចំណូលពុំមែនសារពើពន្ធដទៃទៀតដែល ខេត្ត ក្រុង បានប្រមូលក្រៅពីការអនុញ្ញាតដោយច្បាប់ ក៏ត្រូវបង់ចូលថវិកាខេត្ត ក្រុងដែរ ចៀសវាងទុកចំណូលនោះដោយឡែកសំរាប់ចំណាយដោយឡែក គ្មានតម្លាភាព ។ ចំពោះមុខសញ្ញាចំណូលដែលបានកំណត់រួចហើយ បើក្នុងលក្ខណៈដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើអោយមានតម្លាភាពពិតប្រាកដ មិនត្រូវបង្កើតការដេញថ្លៃតែរូបភាពនោះទេ ទន្ទឹមនោះត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលអោយបានត្រឹមត្រូវតាមការកំណត់ដែលចែងក្នុងកិច្ចសន្យា ។

### ៣. ចំណូលឧបត្ថម្ភពីថវិការដ្ឋ

ចំពោះខេត្ត ក្រុង ដែលត្រូវបំពេញតុល្យភាពដោយការឧបត្ថម្ភពីថវិការដ្ឋ ទោះបីបានកត់ត្រាតួលេខចំណូលឧបត្ថម្ភពីថវិការដ្ឋនៅក្នុងគំរោងថវិការបស់ខ្លួនក៏ដោយ ក៏មិនមានន័យថាថវិការដ្ឋត្រូវតែដាច់ខាតឧបត្ថម្ភតាមចំនួននោះទេ ។ ចំណូលឧបត្ថម្ភពីថវិការដ្ឋ គឺត្រូវពិនិត្យឧបត្ថម្ភជូនខេត្ត ក្រុងដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃថវិការដ្ឋ និងទៅតាមសភាពការណ៍ជាក់ស្តែងនៃការអនុវត្តចំណូល ចំណាយថវិការបស់ខេត្ត ក្រុង ។ ដូច្នេះខេត្ត ក្រុងត្រូវខិតខំជំរុញបង្កើនចំណូលផ្ទៃក្នុងរបស់ខ្លួន ដើម្បីរួមចំណែកបង្កើនការអភិវឌ្ឍន៍ខេត្ត ក្រុង សំរាប់កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងកាត់បន្ថយការផ្តល់ឧបត្ថម្ភពីថវិការដ្ឋ ។

នៅក្នុងការគ្រប់គ្រងថវិកាខេត្ត ក្រុង សំរាប់ឆ្នាំ ២០០២ នេះ ចំណូលឧបត្ថម្ភពីថវិការដ្ឋត្រូវបានពិនិត្យ និងផ្តល់ជូនទៅតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ÷

#### ៣.១ ចំណូលឧបត្ថម្ភពីថវិការដ្ឋសំរាប់ដំណើរការ

ចំពោះចំណូលនេះ ខេត្ត ក្រុងត្រូវធ្វើសំណើសុំឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសនីមួយៗ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ។ នៅដើមត្រីមាសទី ១ នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្តល់ថវិកាឧបត្ថម្ភតុល្យភាពជូនខេត្ត ក្រុង ដោយផ្អែកលើមូលដ្ឋាន ៣/១២ នៃគំរោងឧបត្ថម្ភតុល្យភាពប្រចាំឆ្នាំ ដោយឡែកសំរាប់ត្រីមាសទី ២ ទី ៣ និងទី ៤ ខេត្ត ក្រុងត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភតុល្យភាពនៅដើមខែនៃចុងត្រីមាសមុន សំរាប់ត្រីមាសបន្ទាប់ ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតយុត្តិការដូចតទៅ ÷

- តារាងក្របខ័ណ្ឌមន្ត្រីរាជការ និងមន្ត្រីភូមិ ឃុំ ឬ សង្កាត់ ប្រចាំខែ (តាមតារាងគំរូឆ្នាំ ២០០០)
- របាយការណ៍សរុបចំណូល ចំណាយជាក់ស្តែងរហូតដល់ខែចុងក្រោយ ដោយមានហត្ថលេខាបញ្ជាក់ពីរតនាគារខេត្ត ក្រុង (តាមតារាងគំរូឆ្នាំ ២០០០)

- តារាងប៉ាន់ស្មានចំណូល (តាមតារាងគំរូឆ្នាំ ២០០០) តារាងចំណូលនេះ ត្រូវធ្វើការប៉ាន់ស្មានចំណូលដោយយោងទៅលើតារាងការគិតថវិកា និងបែងចែកតាមខែនីមួយៗ រួចត្រូវប៉ាន់ស្មានជាតួលេខរួមប្រចាំត្រីមាសទៀត ។ តួលេខចំណូលដែលប៉ាន់ស្មាននេះ ត្រូវផ្អែកលើតារាងប៉ាន់ស្មានចំណូល ដែលធ្វើឡើងដោយសាមីអង្គភាពជំនាញពាក់ព័ន្ធដែលគ្រប់គ្រងប្រមូលចំណូលផ្ទាល់ ហើយភ្ជាប់តារាងរបស់សាមីអង្គភាពនោះមកជាមួយផង ។

- តារាងប៉ាន់ស្មានចំណាយ (តាមតារាងគំរូឆ្នាំ ២០០០) តារាងចំណាយនេះ ត្រូវវាយលំអិតតាមមាតិកាថវិកានិងគ្រោងតាមខែនីមួយៗ មិនត្រូវធ្វើគំរោងជាតួលេខរួមមួយត្រីមាសឡើយ ។ ចំពោះចំណាយជាគុណប្រយោជន៍របស់ខេត្ត ក្រុង (ចំណាយដោយឡែករបស់ផ្នែក ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤) ត្រូវភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិតតាមការដ្ឋាននីមួយៗ ដូចជា: ការរៀបចំថែទាំផ្លូវ ប្រព័ន្ធបញ្ចេញបញ្ចូលទឹក សួនច្បារ ច្រាំងទន្លេ....។ល។

#### ៣.២ ចំណូលឧបត្ថម្ភពីថវិការដ្ឋសំរាប់វិនិយោគសាធារណៈ

ចំណូលនេះ គ្រាន់តែជាការផ្ទេរនូវកម្មវិធីចំណាយវិនិយោគសាធារណៈរបស់ថវិការដ្ឋ ទៅអនុវត្តនៅក្នុងថវិកាខេត្ត ក្រុង ដូច្នេះពេលស្នើសុំ គឺខេត្ត ក្រុង ត្រូវធ្វើសំណើត្រង់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែម្តង ។ ការស្នើនេះ ចែកចេញជាពីរយ៉ាង ÷

ទី១. ឧបត្ថម្ភសំរាប់មូលនិធិបដិភាគ ( ជំពូក ៣១ ប្រការ ០២) ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិកាខេត្ត ក្រុង ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវគំរោងកម្មវិធីវិនិយោគ នៃហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលត្រូវអនុវត្តនៅខេត្ត ក្រុងរបស់ខ្លួន ។

ទី២. ឧបត្ថម្ភវិនិយោគដោយថវិការដ្ឋ (ជំពូក ៣១ ប្រការ ០៤) ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិកាខេត្ត ក្រុង ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវឯកសារដែលបានធ្វើលទ្ធកម្មសាធារណៈរួចតាមការដ្ឋាននីមួយៗ ។

ដោយឡែកសំរាប់កម្មវិធីសិលា ចាប់ពីឆ្នាំ ២០០២ តទៅ ថវិការដ្ឋបញ្ឈប់ការផ្ទេរទៅអនុវត្តនៅក្នុងថវិកាខេត្ត ក្រុងទៀតហើយ ដោយថវិការដ្ឋធ្វើការផ្ទេរកម្មវិធីវិនិយោគនេះ ទៅអនុវត្តនៅក្នុងថវិកាឃុំ សង្កាត់វិញ ។

## ខ. អំពីចំណាយ

១. **ចំណាយចរន្ត** : ចំណាយចរន្តត្រូវអនុវត្តអោយបានម៉ឺងម៉ាត់ ទៅតាមគោលការណ៍និងនីតិវិធីដូចគ្នានៃចំណាយថវិការដ្ឋដែរ ពោលគឺ ÷

- អំពីចំណាយបៀវត្សត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់
- អំពីចំណាយតូចតាច និងចំណាយចាំបាច់បន្ទាន់ គឺត្រូវអនុវត្តតាមរយៈរដ្ឋទេយ្យបុរេប្រទានដែលកំណត់ឡើងដោយដីការបស់ខេត្ត ក្រុង ។ ពេលដកប្រាក់ពីរតនាគារ រដ្ឋទេយ្យករត្រូវមានប័ណ្ណដកប្រាក់ និងលិខិតឧទ្ទេសនាមរបស់អង្គភាព (ពុំចាំបាច់ធ្វើលិខិតស្នើសុំឆ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ) ។
- អំពីចំណាយចរន្តផ្សេងៗទៀត គឺត្រូវអនុវត្តទៅតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ ក្រោយពេលដែលទំនិញ ឬ សេវានានាត្រូវបានអនុវត្តរួចហើយ ។
- ចំពោះចំណាយឧបត្ថម្ភមន្ត្រីភូមិ ឃុំ សង្កាត់ ថវិការដ្ឋនឹងធ្វើការផ្ទេរទៅអនុវត្តនៅក្នុងថវិកាឃុំ សង្កាត់វិញ នៅពេលដែលថវិកាឃុំ សង្កាត់ចាប់ដំណើរការ ។ ចំពោះឥណទានថវិកាដែលនៅសល់ ត្រូវបង្វែរទៅចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ។

២. **ចំណាយជាមូលធន** : ចំពោះការចំណាយជាមូលធនគឺចែកចេញជាពីរ ÷

ទី១. ចំណាយសំរាប់មូលនិធិបដិភាគ : ក្នុងពេលអនុវត្ត ខេត្ត ក្រុងត្រូវធ្វើអាណត្តិដោយគ្រាន់តែភ្ជាប់តាមនូវគំរោងកម្មវិធីវិនិយោគនៃហិរញ្ញប្បទានពីក្រៅប្រទេសតែប៉ុណ្ណោះ ។ រតនាគារខេត្ត ក្រុង ត្រូវបើកផ្តល់ ឬផ្ទេរឥណទាននេះទៅក្នុងគណនីម្ចាស់ជំនួយនៅរតនាគារខេត្ត ក្រុង ឬធនាគារ (បើមាន) ។

ទី២. ចំណាយវិនិយោគ : ចំណាយវិនិយោគ ទោះជាហិរញ្ញប្បទានដោយថវិកាខេត្ត ក្រុង ឬហិរញ្ញប្បទានដោយថវិការដ្ឋឧបត្ថម្ភក៏ដោយ គឺត្រូវតែបំពេញបែបបទ និងអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីលទ្ធកម្មសាធារណៈ ជាធរមាន ។

៣. **ចំណាយបន្ថែមលើសពីគំរោងចំណាយថវិកាខេត្ត ក្រុងប្រចាំឆ្នាំ** : យោងប្រការ ១២ នៃប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង បានចែងថា “នៅក្នុងឆ្នាំថវិកា ប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់ខេត្ត ក្រុង បានកើនឡើងខ្ពស់ជាងគំរោងចំណូលដែលបានគ្រោងទុកនោះ ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកំរិតចំណូលលើសដែលបានចុះកិច្ចបញ្ជីការ” ។

ដូច្នេះ នៅដើមខែតុលា ខេត្ត ក្រុងត្រូវធ្វើការប៉ាន់ស្មានការអនុវត្តចំណូលប្រចាំឆ្នាំរបស់ខ្លួន ដោយមានមូលដ្ឋានជាក់លាក់ ដែលអាចប្រមូលចំណូលបានយ៉ាងពិតប្រាកដ រួចប្រៀបធៀបជាមួយគំរោងចំណូលប្រចាំឆ្នាំ ។ ប្រសិនបើមានចំណូលលើសពីគំរោងចំណូលប្រចាំឆ្នាំ ខេត្ត ក្រុងអាចស្នើសុំបន្ថែមគំរោងចំណាយប្រចាំឆ្នាំ សំរាប់ចំណាយជាគុណប្រយោជន៍របស់ខេត្ត ក្រុង ដែលជាចំណាយសំរាប់វិនិយោគអភិវឌ្ឍន៍ខេត្ត ក្រុង ហើយខេត្ត ក្រុងត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិតតាមការដ្ឋាននីមួយៗផង ។

## គ. ការបង្វែរឥណទានផ្ទៃក្នុងជំពូក

យោងប្រការ ១៣ វាក្យខ័ណ្ឌទី ២ នៃប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីបទបញ្ញាថវិការបស់ខេត្ត ក្រុង បានចែងថា "ការបង្វែរពីប្រការមួយទៅប្រការមួយ ពីកថាខ័ណ្ឌមួយទៅកថាខ័ណ្ឌមួយ និងពីវាក្យខ័ណ្ឌមួយទៅវាក្យខ័ណ្ឌមួយ ដែលនៅក្នុងជំពូកតែមួយ ត្រូវធ្វើឡើងដោយដីការបស់អភិបាលខេត្ត ក្រុង បន្ទាប់ពីមានការឯកភាពរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ..." ។ ប៉ុន្តែ ខេត្ត ក្រុងមិនត្រូវបង្វែរឥណទានពីជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤ (ចំណាយដោយឡែករបស់ផ្នែក) ទៅចំណាយនៅកថាខ័ណ្ឌផ្សេងៗទៀត នៃជំពូក ១១ ដែលជាហេតុធ្វើអោយចំណាយសំរាប់ដំណើរការរដ្ឋបាល មានការកើនឡើងខ្ពស់ឡើយ ហើយធ្វើអោយចំណាយសំរាប់ជាគុណប្រយោជន៍ខេត្ត ក្រុងថយចុះនោះទេ ប្រៀបធៀបនឹងគំរោងប្រចាំឆ្នាំ ។ បើក្នុងករណីចាំបាច់ដែលខេត្ត ក្រុងមានសំណូមពរចង់បង្វែរឥណទានថវិកាដែលមាននៅក្នុងខ្ទង់ចំណាយគុណប្រយោជន៍ខេត្ត ក្រុង (ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤) ទៅបង្កើនឥណទានថវិកាអោយកថាខ័ណ្ឌផ្សេងៗទៀតនៃជំពូក ១១ នោះ ខេត្ត ក្រុងត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ម្យ៉ាងទៀត ក្នុងការអនុវត្តចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ខេត្ត ក្រុងត្រូវអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីហិរញ្ញវត្ថុ និងទៅតាមគំរោងចំណាយនៃការដ្ឋាននីមួយៗ ដែលខេត្ត ក្រុងបានលើកក្នុងផែនការអភិវឌ្ឍន៍ និងមានការពិភាក្សាឯកភាពពីក្រសួងមហាផ្ទៃរួចហើយ ។ នៅពេលអនុវត្ត ប្រសិនបើខេត្ត ក្រុងមានការចាំបាច់ត្រូវផ្លាស់ប្តូរគំរោងចំណាយនៃការដ្ឋានណាមួយនោះ ខេត្ត ក្រុងត្រូវស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន ទើបអាចចាប់ផ្តើមអនុវត្តគំរោងចំណាយសំរាប់ការដ្ឋានថ្មីបាន ។

ខាងលើនេះ គឺជាប្រកាសណែនាំបន្ថែមក្នុងកិច្ចប្រតិបត្តិការថវិកាខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដោយឡែកប្រកាសណែនាំស្តីពីកិច្ចប្រតិបត្តិការអនុវត្តថវិកាខេត្ត ក្រុង លេខ ២០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ នៅតែរក្សាសុពលភាពដដែល ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០២

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត ក្រុង
- គ្រប់រតនាគារខេត្ត ក្រុង
- គ្រប់សាខាពន្ធដារខេត្ត ក្រុង
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២០៣ សហវ.ស

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មករា ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបន្ថែមទុនរបស់រដ្ឋ ក្នុងសហគ្រាសឱសថកម្ពុជា "ស.ឱ.ក"

****************

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

-បានឃើញកតិកាសញ្ញា នៃម្ចាស់ភាគហ៊ុនក្រុមហ៊ុនចំរុះដែលមានភាគកម្មសាធារណៈចំនួនតិចមានឈ្មោះថា សហគ្រាសឱសថកម្ពុជា "ស.ឱ.ក" ចុះខែមិនា ឆ្នាំ១៩៩៨

-បានឃើញលក្ខន្តិកៈក្រុមហ៊ុនចំរុះដែលមានភាគកម្មសាធារណៈចំនួនតិចមានឈ្មោះថា សហគ្រាសឱសថកម្ពុជា "ស.ឱ.ក" ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ១៩៩៨

-តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃសហគ្រាសឱសថកម្ពុជា នាសម័យប្រជុំលើកទី២ អាណត្តិទី១ ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០០១

# សំរេច

**ប្រការ ១ :** យល់ព្រមបន្ថែមទុនជាសំភារៈផលិតកម្មបណ្តាញថ្នាំគ្រាប់និង ឧបករណ៍បណ្តាញត្រជាក់ ដែលមានតំលៃ ៧៥០.៥៥៨,៤៣ USD ( ប្រាំពីររយហាសិបពាន់ប្រាំបួនរយហាសិបប្រាំបីដុល្លារអាមេរិក និងសែសិបបីសេន ) សរុបភាគហ៊ុនរបស់រាជរដ្ឋាភិបាលចំនួន ៩៣៣.៥៥៣,៩៥ USD ( ប្រាំបួនរយសាមសិបបីពាន់ប្រាំរយហាសិបបី ដុល្លារអាមេរិក និងកៅសិបប្រាំសេន) ។

**ប្រការ ២ :** អគ្គនាយកសហគ្រាសឱសថកម្ពុជា និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

**ប្រការ ៣ :** ប្រកាសនេះមានប្រសិទ្ធភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **ទេសរដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងសុខាភិបាល** |
| **គាត ឈន់** | **វេជ្ជ.ហុង_ស៊ុនហួត** |

ចំលងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ០២៣ MoC / M 2002

ភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីលទ្ធផល នៃ ការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០២

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម ។
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ខ្សែន សរសៃសិប្បនិម្មិតធ្វើពីដែមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ និងការបន្តសុពលភាពនៃកិច្ចព្រមព្រៀងនេះ តាមអនុស្សារណៈនៃការយោគយល់គ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១។
- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ០១៣ MoC/M2002 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២ ស្តីពីការដាក់អោយដេញថ្លៃ លើកូតាសំលៀកបំពាក់ដែលត្រូវនាំចេញទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០២ ។
- យោងតាមការចាំបាច់នៃការងារ ។

## សំរេច

**ប្រការ ១ :** ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទសំលៀកបំពាក់នីមួយ ៗ សំរាប់ការនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០២ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០២ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ A ។

**ប្រការ ២ :** ក្រុមហ៊ុនទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ A នៃប្រការ ១ ត្រូវបង់ប្រាក់បន្ថែម ៩០% អោយបានមុនថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០២ ។ ការខកខានបង់ នឹងអាចនាំអោយមានការរឹបអូសប្រាក់កក់ ១០% និងការបង្វិលកូតាដែលដេញបានយកទៅទុកដេញថ្លៃ នៅលើកក្រោយវិញ ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការមិនអនុញ្ញាតអោយក្រុមហ៊ុននោះចូលរួមក្នុងការដេញថ្លៃកូតាលើកក្រោយៗទៀត ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

<u>ចំលងជូន :</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

  " ដើម្បីជ្រាបជាពតិមាន "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ANNEX - A**

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

2:19 PM, 1/28/02

**MINISTRY OF COMMERCE**

TENDER of QUOTA

# TENDER of QUOTA
## January 28,2002

| ID | COMPANY NAME | 334/634 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 82,000 | $3.00 | | | |
| 1 | FY Cambodia | 1,000 | $7.40 | $7,400.00 | $740.00 | $6,660.00 |
| 2 | QMI | 16,000 | $6.60 | $105,600.00 | $10,560.00 | $95,040.00 |
| 3 | W&D Cambodia Garment | 30,000 | $6.00 | $180,000.00 | $18,000.00 | $162,000.00 |
| 4 | Siu Quinh | 400 | $5.00 | $2,000.00 | $200.00 | $1,800.00 |
| 5 | Oceanic | 3,000 | $4.60 | $13,800.00 | $1,380.00 | $12,420.00 |
| 6 | Cung Sing | 1,000 | $4.60 | $4,600.00 | $460.00 | $4,140.00 |
| 7 | Roo Hsing | 10,000 | $4.20 | $42,000.00 | $4,200.00 | $37,800.00 |
| 8 | Tai Yar Garment | 5,000 | $4.20 | $21,000.00 | $2,100.00 | $18,900.00 |
| 9 | Chu Hsing | 6,686 | $4.00 | $26,744.00 | $2,674.40 | $24,069.60 |
| 10 | Hechter | 4,457 | $4.00 | $17,828.00 | $1,782.80 | $16,045.20 |
| 11 | South Bay | 891 | $4.00 | $3,564.00 | $356.40 | $3,207.60 |
| 12 | Kennetex | 446 | $4.00 | $1,784.00 | $178.40 | $1,605.60 |
| 13 | MJTS | 891 | $4.00 | $3,564.00 | $356.40 | $3,207.60 |
| 14 | Vinstar Garment | 2,229 | $4.00 | $8,916.00 | $891.60 | $8,024.40 |
| | **TOTAL** | **82,000** | | **$438,800.00** | **$43,880.00** | **$394,920.00** |

| ID | COMPANY NAME | 335/635 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 25,000 | $3.00 | | | |
| 1 | Marlyn | 300 | $12.00 | $3,600.00 | $360.00 | $3,240.00 |
| 2 | King First | 242 | $11.00 | $2,662.00 | $266.20 | $2,395.80 |
| 3 | QMI | 3,200 | $9.80 | $31,360.00 | $3,136.00 | $28,224.00 |
| 4 | Cheer View | 1,000 | $9.00 | $9,000.00 | $900.00 | $8,100.00 |
| 5 | In Fong | 5,000 | $8.60 | $43,000.00 | $4,300.00 | $38,700.00 |
| 6 | FY Cambodia | 700 | $8.20 | $5,740.00 | $574.00 | $5,166.00 |
| 7 | Suit Way | 2,000 | $8.00 | $16,000.00 | $1,600.00 | $14,400.00 |
| 8 | Grace Sun | 54 | $8.00 | $432.00 | $43.20 | $388.80 |
| 9 | New Point World Trade | 5,000 | $8.00 | $40,000.00 | $4,000.00 | $36,000.00 |
| 10 | New Orient | 5,000 | $8.00 | $40,000.00 | $4,000.00 | $36,000.00 |
| 11 | Kennetex | 2,000 | $6.80 | $13,600.00 | $1,360.00 | $12,240.00 |
| 12 | Gold Fame | 504 | $6.20 | $3,124.80 | $312.48 | $2,812.32 |
| | **TOTAL** | **25,000** | | **$208,518.80** | **$20,851.88** | **$187,666.92** |

| ID | COMPANY NAME | 338/339 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 450,000 | $3.00 | | | |
| 1 | Great Lancelot | 100,000 | $6.00 | $600,000.00 | $60,000.00 | $540,000.00 |
| 2 | Hung Wah | 50,000 | $6.00 | $300,000.00 | $30,000.00 | $270,000.00 |
| 3 | Yung Wah Industrial | 100,000 | $6.00 | $600,000.00 | $60,000.00 | $540,000.00 |
| 4 | Winner Knitting | 40,000 | $5.40 | $216,000.00 | $21,600.00 | $194,400.00 |
| 5 | M S Int'l Garment | 50,000 | $5.40 | $270,000.00 | $27,000.00 | $243,000.00 |
| 6 | PCCS | 100,000 | $5.20 | $520,000.00 | $52,000.00 | $468,000.00 |
| 7 | Franco | 1,228 | $5.00 | $6,140.00 | $614.00 | $5,526.00 |
| 8 | Ming Hoi | 8,772 | $5.00 | $43,860.00 | $4,386.00 | $39,474.00 |
| | **TOTAL** | **450,000** | | **$2,556,000.00** | **$255,600.00** | **$2,300,400.00** |

**ANNEX - A** ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE 2:19 PM, 1/28/02

| ID | COMPANY NAME | 340/640 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 200,000 | $2.00 | | | |
| 1 | South Bay | 20,000 | $2.20 | $44,000.00 | $4,400.00 | $39,600.00 |
| 2 | MSI | 40,000 | $2.00 | $80,000.00 | $8,000.00 | $72,000.00 |
| | TOTAL | 60,000 | | $124,000.00 | $12,400.00 | $111,600.00 |

| ID | COMPANY NAME | 345 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 28,000 | $3.00 | | | |
| 1 | Mighti Spectra | 6,000 | $14.00 | $84,000.00 | $8,400.00 | $75,600.00 |
| 2 | Winner Knitting | 5,000 | $8.00 | $40,000.00 | $4,000.00 | $36,000.00 |
| 3 | Universal Apparel | 5,000 | $6.80 | $34,000.00 | $3,400.00 | $30,600.00 |
| 4 | Sam Han Cambodia | 12,000 | $6.00 | $72,000.00 | $7,200.00 | $64,800.00 |
| | TOTAL | 28,000 | | $230,000.00 | $23,000.00 | $207,000.00 |

| ID | COMPANY NAME | 347/348/647/648 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 880,000 | $3.00 | | | |
| 1 | FY Cambodia | 8,000 | $7.20 | $57,600.00 | $5,760.00 | $51,840.00 |
| 2 | Suit Way | 5,000 | $6.00 | $30,000.00 | $3,000.00 | $27,000.00 |
| 3 | Da Joo | 2,085 | $6.00 | $12,510.00 | $1,251.00 | $11,259.00 |
| 4 | Roo Hsing | 70,000 | $6.00 | $420,000.00 | $42,000.00 | $378,000.00 |
| 5 | Top One | 40,000 | $5.40 | $216,000.00 | $21,600.00 | $194,400.00 |
| 6 | European Trend Fashion | 40,000 | $5.20 | $208,000.00 | $20,800.00 | $187,200.00 |
| 7 | PCCS | 50,000 | $5.00 | $250,000.00 | $25,000.00 | $225,000.00 |
| 8 | Ho Hing Garment | 40,000 | $5.00 | $200,000.00 | $20,000.00 | $180,000.00 |
| 9 | M S Int'l Garment | 3,000 | $5.00 | $15,000.00 | $1,500.00 | $13,500.00 |
| 10 | Best Honour | 30,000 | $4.60 | $138,000.00 | $13,800.00 | $124,200.00 |
| 11 | MSI | 5,000 | $4.40 | $22,000.00 | $2,200.00 | $19,800.00 |
| 12 | Sino Nature | 10,000 | $4.20 | $42,000.00 | $4,200.00 | $37,800.00 |
| 13 | Su Tong Fang | 50,000 | $4.20 | $210,000.00 | $21,000.00 | $189,000.00 |
| 14 | Evergreen | 10,000 | $4.20 | $42,000.00 | $4,200.00 | $37,800.00 |
| 15 | W&D Cambodia Garment | 250 | $4.00 | $1,000.00 | $100.00 | $900.00 |
| 16 | Gennon | 15,000 | $4.00 | $60,000.00 | $6,000.00 | $54,000.00 |
| 17 | Sharp Casual | 60,000 | $4.00 | $240,000.00 | $24,000.00 | $216,000.00 |
| 18 | Tai Yar Garment | 5,000 | $4.00 | $20,000.00 | $2,000.00 | $18,000.00 |
| 19 | Vinstar Garment | 5,000 | $3.80 | $19,000.00 | $1,900.00 | $17,100.00 |
| 20 | Marlyn | 5,000 | $3.60 | $18,000.00 | $1,800.00 | $16,200.00 |
| 21 | Kin Tai | 30,000 | $3.60 | $108,000.00 | $10,800.00 | $97,200.00 |
| 22 | City New | 4,000 | $3.60 | $14,400.00 | $1,440.00 | $12,960.00 |
| 23 | United Faith | 100,000 | $3.60 | $360,000.00 | $36,000.00 | $324,000.00 |
| 24 | Hang Fung Shing | 1,944 | $3.60 | $6,998.40 | $699.84 | $6,298.56 |
| 25 | K & A Garment | 20,000 | $3.60 | $72,000.00 | $7,200.00 | $64,800.00 |
| 26 | Top World Garment Co Ltd | 15,000 | $3.40 | $51,000.00 | $5,100.00 | $45,900.00 |
| 27 | King First | 1,500 | $3.40 | $5,100.00 | $510.00 | $4,590.00 |
| 28 | PYL | 2,000 | $3.40 | $6,800.00 | $680.00 | $6,120.00 |
| 29 | Gold Kamvimex | 6,000 | $3.40 | $20,400.00 | $2,040.00 | $18,360.00 |
| 30 | Kennetex | 24,000 | $3.40 | $81,600.00 | $8,160.00 | $73,440.00 |
| 31 | Tai Yang | 60,000 | $3.40 | $204,000.00 | $20,400.00 | $183,600.00 |
| 32 | PDC Garment Ltd | 15,020 | $3.20 | $48,064.00 | $4,806.40 | $43,257.60 |
| 33 | Sportex | 15,020 | $3.20 | $48,064.00 | $4,806.40 | $43,257.60 |
| 34 | Great Union Cambodia Garment Co Ltd | 7,510 | $3.20 | $24,032.00 | $2,403.20 | $21,628.80 |
| 35 | Oceanic | 3,755 | $3.20 | $12,016.00 | $1,201.60 | $10,814.40 |
| 36 | Wearwel | 7,510 | $3.20 | $24,032.00 | $2,403.20 | $21,628.80 |

**ANNEX - A** ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE 2:19 PM, 1/28/02

| | | | | | | |
|---|---|---|---|---|---|---|
| 37 | South Bay | 15,020 | $3.20 | $48,064.00 | $4,806.40 | $43,257.60 |
| 38 | You Cheng | 2,253 | $3.20 | $7,209.60 | $720.96 | $6,488.64 |
| 39 | New Point World Trade | 15,020 | $3.20 | $48,064.00 | $4,806.40 | $43,257.60 |
| 40 | New Orient | 3,756 | $3.20 | $12,019.20 | $1,201.92 | $10,817.28 |
| 41 | Cambodia Sportwear | 37,551 | $3.20 | $120,163.20 | $12,016.32 | $108,146.88 |
| 42 | Tack Fat | 37,551 | $3.20 | $120,163.20 | $12,016.32 | $108,146.88 |
| 43 | MJTS | 2,255 | $3.20 | $7,216.00 | $721.60 | $6,494.40 |
| | TOTAL | 880,000 | | $3,670,515.60 | $367,051.56 | $3,303,464.04 |

| ID | COMPANY NAME | 352/652 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 300,000 | $0.50 | | | |
| 1 | Wilson Garment | 41,667 | $0.70 | $29,166.90 | $2,916.69 | $26,250.21 |
| 2 | Cambodia Apparel | 3,200 | $0.70 | $2,240.00 | $224.00 | $2,016.00 |
| 3 | United Arts | 50,000 | $0.50 | $25,000.00 | $2,500.00 | $22,500.00 |
| | TOTAL | 94,867 | | $56,406.90 | $5,640.69 | $50,766.21 |

| ID | COMPANY NAME | 435 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 9,000 | $2.00 | | | |
| 1 | FY Cambodia | 1,000 | $12.20 | $12,200.00 | $1,220.00 | $10,980.00 |
| 2 | Su Tong Fang | 5,000 | $5.00 | $25,000.00 | $2,500.00 | $22,500.00 |
| 3 | Flying Dragon | 3,000 | $4.40 | $13,200.00 | $1,320.00 | $11,880.00 |
| | TOTAL | 9,000 | | $50,400.00 | $5,040.00 | $45,360.00 |

| ID | COMPANY NAME | 438 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 26,000 | $2.00 | | | |
| 1 | Mighti Spectra | 2,000 | $10.00 | $20,000.00 | $2,000.00 | $18,000.00 |
| 2 | Universal Apparel | 11,000 | $7.00 | $77,000.00 | $7,700.00 | $69,300.00 |
| 3 | Pak Shun | 13,000 | $5.00 | $65,000.00 | $6,500.00 | $58,500.00 |
| | TOTAL | 26,000 | | $162,000.00 | $16,200.00 | $145,800.00 |

| ID | COMPANY NAME | 445/446 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 42,000 | $0.50 | | | |
| 1 | Winner Knitting | 5,000 | $3.00 | $15,000.00 | $1,500.00 | $13,500.00 |
| 2 | Century Rich Co Ltd | 5,000 | $1.00 | $5,000.00 | $500.00 | $4,500.00 |
| 3 | M&V Int'l MFG Ltd | 3,000 | $0.50 | $1,500.00 | $150.00 | $1,350.00 |
| | TOTAL | 13,000 | | $21,500.00 | $2,150.00 | $19,350.00 |

| ID | COMPANY NAME | 638/639 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 280,000 | $1.00 | | | |
| 1 | Marlyn | 3,000 | $2.00 | $6,000.00 | $600.00 | $5,400.00 |
| 2 | Fortune | 15,000 | $2.00 | $30,000.00 | $3,000.00 | $27,000.00 |
| 3 | South Bay | 20,000 | $2.00 | $40,000.00 | $4,000.00 | $36,000.00 |
| 4 | Evergreen | 20,000 | $1.80 | $36,000.00 | $3,600.00 | $32,400.00 |
| 5 | FY Cambodia | 6,000 | $1.60 | $9,600.00 | $960.00 | $8,640.00 |
| 6 | Wing Hang | 937 | $1.60 | $1,499.20 | $149.92 | $1,349.28 |
| 7 | Cambotex HK | 10,000 | $1.60 | $16,000.00 | $1,600.00 | $14,400.00 |
| 8 | S.H Int'l Garment | 50,000 | $1.60 | $80,000.00 | $8,000.00 | $72,000.00 |
| 9 | M S Int'l Garment | 100,000 | $1.60 | $160,000.00 | $16,000.00 | $144,000.00 |
| 10 | Fame Cambodia | 3,000 | $1.40 | $4,200.00 | $420.00 | $3,780.00 |

**ANNEX - A** ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE 2:19 PM, 1/28/02

| | | | | | | |
|---|---|---|---|---|---|---|
| 11 | PYL | 2,100 | $1.40 | $2,940.00 | $294.00 | $2,646.00 |
| 12 | Sin Lan Ho Garment | 30,000 | $1.40 | $42,000.00 | $4,200.00 | $37,800.00 |
| 13 | Hechter | 10,000 | $1.20 | $12,000.00 | $1,200.00 | $10,800.00 |
| 14 | Universal Apparel | 3,000 | $1.20 | $3,600.00 | $360.00 | $3,240.00 |
| 15 | MJTS | 3,000 | $1.20 | $3,600.00 | $360.00 | $3,240.00 |
| 16 | Franco | 1,132 | $1.00 | $1,132.00 | $113.20 | $1,018.80 |
| 17 | Splendid Chance | 472 | $1.00 | $472.00 | $47.20 | $424.80 |
| 18 | King First | 377 | $1.00 | $377.00 | $37.70 | $339.30 |
| 19 | Roa Yuan | 566 | $1.00 | $566.00 | $56.60 | $509.40 |
| 20 | New Orient | 944 | $1.00 | $944.00 | $94.40 | $849.60 |
| 21 | Sabrina | 472 | $1.00 | $472.00 | $47.20 | $424.80 |
| TOTAL | | 280,000 | | $451,402.20 | $45,140.22 | $406,261.98 |

| ID | COMPANY NAME | 645/646 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 170,000 | $0.50 | | | |
| 1 | Winner Knitting | 5,000 | $0.90 | $4,500.00 | $450.00 | $4,050.00 |
| 2 | Pak Shun | 15,000 | $0.70 | $10,500.00 | $1,050.00 | $9,450.00 |
| 3 | Gold Fame | 10,000 | $0.70 | $7,000.00 | $700.00 | $6,300.00 |
| 4 | M&V Int'l MFG Ltd | 3,000 | $0.50 | $1,500.00 | $150.00 | $1,350.00 |
| 5 | Fortune | 15,000 | $0.50 | $7,500.00 | $750.00 | $6,750.00 |
| TOTAL | | 48,000 | | $31,000.00 | $3,100.00 | $27,900.00 |

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :.........៣៤.........បទ.ប្រក.

ភ្នំពេញ, ថ្ងៃទី២៥ ខែមករា ឆ្នាំ ២០០២

## ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំ ស្តីពី ការធ្វើអាជីវកម្ម ប្រៃសណីយ៍អាស៊ានលើកទី ៩

( 9th ASEAN POSTAL BUSINESS MEETING )

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-យោងលិខិតលេខ ១៧១៣ សជណគប ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញការងារចាំបាច់របស់ក្រសួង

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការកណ្តាលមួយរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | រស់ សម៉យ | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-លោក | កុយ ពុំ | នាយកខុទ្ទកាល័យ | អនុប្រធានទី១ |

| | | | |
|---|---|---|---|
| ៣-លោក | ព្រុំ សុន្ថា | អនុប្រធានក្តាប់រួមនាយកដ្ឋានប្រៃសណីយ៍ | អនុប្រធានទី២ |
| ៤-លោក | កែវ វុឌ្ឍិន | អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ | សមាជិក |
| ៥-លោក | ព្រាប សុរិទ្ធី | អនុប្រធាននាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ៦-លោក | អៀង ស្រេង | អនុប្រធាននាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ៧-លោក | ឈី សុខា | អនុប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ | សមាជិក |
| ៨-លោក | ប៉ុក សូផាត | ប្រធានការិយាល័យរដ្ឋបាល នៃខុទ្ទកាល័យ | សមាជិក |
| ៩-អ្នកស្រី | លីប លឿង | ប្រធានការិយាល័យហិរញ្ញវត្ថុ នៃនាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ១០-លោក | វង្ស ស៊ីម | ប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ១១-លោក | អាំ សំអាត | ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តសៀមរាប | សមាជិក |

ប្រការ ២ : គណៈកម្មការកណ្តាល មានភារៈកិច្ចដឹកនាំរួមក្នុងការរៀបចំកិច្ចប្រជុំ ស្តីពីការធ្វើអាជីវកម្មប្រៃសណីយ៍អាស៊ាន លើកទី ៩ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០៩ ដល់ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០២ នៅទីរួមខេត្តសៀមរាប។

ប្រការ ៣ : គណៈកម្មការកណ្តាលនេះអាចបង្កើតអនុគណៈកម្មការជំនាញក្នុងករណីចាំបាច់ណាមួយ ហើយសមាជិកគណៈកម្មការកណ្តាលទាំងអស់ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ ឯកឧត្តមប្រធាន។ នៅពេលចប់ភារៈកិច្ចត្រូវរាយការណ៍ពីលទ្ធផលនៃ កិច្ចប្រជុំ ជូន ឯកឧត្តមរដ្ឋមន្ត្រី ដើម្បីពិនិត្យ និង សំរេច ។

ប្រការ ៤ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ខុទ្ទកាល័យ-អធិការដ្ឋាន-នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ-នាយកដ្ឋានប្រៃសណីយ៍-មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ខេត្តសៀមរាប និងសាម៉ីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

សូ-ឃុន

**កន្លែងទទួល**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-សាលាខេត្តសៀមរាប
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៥ " ដើម្បីអនុវត្តន៍ "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ :..៧៧៤....អយក.ប្រក

# ប្រកាស
ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខនស.រកត.១១៩៨_៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រមលេខ នសរ-កម ០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បកចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧៩៦.៥២ ចុះថ្ងៃទី២៦ កក្កដា ១៩៩៦ ស្តីអំពីប្រព័ន្ធអប់រំចំនេះទូទៅ១២ឆ្នាំ។
- បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ១៨៥២ សជណ.អវ.ចុះថ្ងៃ២៣ ធ្នូ ១៩៩៩ ស្តីពីការលុបប្រលងសញ្ញាប័ត្រមធ្យមសិក្សាលើកទី២។
- យោងតាមការចាំបាច់របស់ ក្រសួងអប់រំ យុវជន និងកីឡា។

### សំរេច

ប្រការ១ _ មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា រៀងរាល់ឆ្នាំសិក្សា។

ប្រការ២_ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង និងនាយកគ្រឹះស្ថានសិក្សាដែលគ្រឹះស្ថានត្រូវបានកំណត់ជាមណ្ឌលប្រលង មានភារៈរៀបចំបន្ទប់ប្រលងនិងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តទៅ នៃការប្រលងអោយហើយស្រេច មុនបើកសម័យប្រលង។

ប្រការ៣_ មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និង សមាជិកមេប្រយោគមួយ

ចំនួនតាមការចាំបាច់នៃមណ្ឌលប្រលង ។

ប្រការ៤_ សមាសភាព និងចំនួនព្រមទាំងលិខិតឧទ្ទេសនាមមេប្រយោគត្រូវសំរេចដោយរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា តាមសំនើរបស់ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះ_ទូទៅ តាមឋានានុក្រម ។

ប្រការ៥_ បន្ទប់ប្រលងនីមួយៗ ត្រូវដាក់បេក្ខជនត្រឹម២៥ "ម្ភៃប្រាំ "នាក់។ បើមានបេក្ខជនទៅសល់ ០៥ "ប្រាំ "នាក់ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក។

ប្រការ៦_ ប្រធានមណ្ឌលនៃមណ្ឌលសំនេរនីមួយៗ ជាអ្នកទទួលខុសត្រូវរួម ក្នុងការដំនើរការ ប្រព្រឹត្តទៅនៃដំនើរការវិញ្ញាសាសរសេរទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសចំពោះ ក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ៧_ ប្រធានមណ្ឌល ត្រូវសហការ ឬធ្វើអន្តរាគមន៍ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត_ក្រុងនៃមណ្ឌលប្រលង ក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រលង ។

ប្រការ៨_ មណ្ឌល ឬ អនុមណ្ឌលប្រលងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍ នៃ ការប្រលង ប្រធានមណ្ឌលនៃមណ្ឌល ឬ អនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មក គណៈមេប្រយោគទូទាំងប្រទេស និងអាជ្ញាធរដែនដីដើម្បីដោះស្រាយ ឬសុំការសំរេច ពីក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ៩_ ប្រធានមណ្ឌល ត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និង សមាជិកមេប្រយោគអោយ ទទួលខុសត្រូវតាមមុខងាររៀងៗខ្លួន។

ប្រការ១០_ ភារកិច្ចគណៈកម្មការ អនុគណៈកម្មការ និងសមាជិកមេប្រយោគនឹងមានចែងក្នុង កំរងភារកិច្ចគណៈមេប្រយោគ។

ប្រការ១១_ នឹងអនុញ្ញាតអោយចុះឈ្មោះប្រលងបាន សិស្សថ្នាក់ទី១២ នៃវិទ្យាល័យសាធារណៈ និង ឯកជនដែលបានរៀន នៅមធ្យមសិក្សាទុតិយភូមិគ្រប់កំរិតថ្នាក់ បានរៀនចប់កម្មវិធី សិក្សាថ្នាក់ទី១២ មានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងគោរពបានត្រឹមត្រូវនូវ បទបញ្ជាផ្ទៃក្នុងសំរាប់គ្រឹះស្ថានមធ្យមសិក្សា ហើយត្រូវបានវាយតំលៃផ្នែកសីលធម៌រស់ នៅប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ ។ ពាក្យសុំចុះឈ្មោះប្រលងមានបិទតែម ត្រូវស្នើសុំ ទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមឋានានុក្រម។

ប្រការ១២_ អាចសុំចុះឈ្មោះប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ជាបេក្ខជនស្វ័យនិទាន អតីតបេក្ខជនដែលបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ។

ប្រការ១៣_ បេក្ខជន ត្រូវភ្ជាប់នឹងពាក្យសុំប្រលងរបស់ខ្លួននូវ ÷

- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ ១សន្លឹក។
- សលាកប័ត្រឯកត្តជនទំហំ១៥ស.ម គុណនឹង ២១ស.ម មានបិទ រូបថតថ្មីថត ចំពីមុខទំហំ៤ស.ម គុណនឹង ៦ស.ម ចំនួន២សន្លឹក ។

- បង្កាន់ដៃបង់សិទ្ធិប្រលង ១ច្បាប់ ។
- រូបថត ថតថ្មី ថតចំពីមុខ ទំហំ៤ស.ម គុណនឹង៦ស.ម" រូបថតដែលបានបិទលើសលាកប័ត្រឯកត្តជន" ចំនួន៣សន្លឹក ។
- សៀវភៅសិក្ខាគារិក" ចំពោះសិស្សសាលាឯកជន" ។

ប្រការ១៤_ ពាក្យសុំចុះឈ្មោះប្រលង នឹងត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សា ដែលខ្លួនសិក្សា។នាយកគ្រឹះស្ថានសិក្សាត្រូវប្រមូលសំនុំលិខិតរបស់បេក្ខជន បញ្ជូនទៅនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុង ដើម្បីធ្វើការបែងចែកនាមត្រកូលបេក្ខជនតាមលំដាប់អក្ខរក្រម (លំដាប់ ព្យញ្ជនៈ និង ស្រៈ) ទៅតាមបន្ទប់ប្រលង។

ប្រការ១៥_ បេក្ខជនស្វ័យរិន ត្រូវដាក់ពាក្យសុំប្រលង ដោយមានបញ្ជាក់សម័យប្រលង មណ្ឌលប្រលង លេខបន្ទប់ លេខតុ នៃសម័យប្រលងមុន នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុងដែលសាមីខ្លួនបានសុំប្រលងពីមុន ឬ នៅនាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

ប្រការ១៦_ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុងត្រូវធ្វើបញ្ជីរាយនាមបេក្ខជន ផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា " នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ " ដើម្បីពិនិត្យសំរេចលើបេក្ខភាព ។

ប្រការ១៧_ បេក្ខជនត្រូវអនុវត្តតាមបទបញ្ញត្តិទូទៅនៃការប្រលង ដែលមានចែងក្នុងអត្ថបទមួយដោយឡែក ។

ប្រការ១៨_ វិញ្ញាសា ថេរវេលា និងពិន្ទុនៃការប្រលង សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នឹងត្រូវបានកំណត់ដូចតទៅ ÷

| | | | |
|---|---|---|---|
| ១_ ភាសាខ្មែរ | រយៈពេល | ១២០នាទី | ត្រូវបានពិន្ទុពី ០ ដល់១០០ |
| ២_ គណិតវិទ្យា | រយៈពេល | ១៥០នាទី | ត្រូវបានពិន្ទុពី ០ ដល់១២៥ |
| ៣_ រូបវិទ្យា | រយៈពេល | ៩០នាទី | ត្រូវបានពិន្ទុពី ០ ដល់៧៥ |
| ៤_ គីមី | រយៈពេល | ៦០នាទី | ត្រូវបានពិន្ទុពី ០ ដល់៥០ |
| ៥_ ជីវវិទ្យា | រយៈពេល | ៦០នាទី | ត្រូវបានពិន្ទុពី ០ ដល់៥០ |
| ៦_ ផែនដីវិទ្យា | រយៈពេល | ៣០នាទី | ត្រូវបានពិន្ទុពី ០ ដល់២៥ |
| ៧_ ប្រវត្តិវិទ្យា | រយៈពេល | ៤៥នាទី | ត្រូវបានពិន្ទុពី ០ ដល់៣៧ |
| ៨_ ភូមិវិទ្យា | រយៈពេល | ៤៥នាទី | ត្រូវបានពិន្ទុពី ០ ដល់៣៨ |
| ៩_ សីលធម៌_ពលរដ្ឋវិជ្ជា | រយៈពេល | ៦០នាទី | ត្រូវបានពិន្ទុពី ០ ដល់៥០ |
| ១០_ សំនួរទំរង់បិទ | រយៈពេល | ៦០នាទី | ត្រូវបានពិន្ទុពី ០ ដល់៥០ |

វិញ្ញាសានីមួយៗនឹងត្រូវបានពិន្ទុសូន្យចំពោះបេក្ខជនអវត្តមាន ឬ បេក្ខជនដែល/

មិនបានប្រគល់សន្លឹកកិច្ចការដល់គណៈមេប្រយោគ។

ប្រការ១៩_ ប្រធានវិញ្ញាសាប្រលង ត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ទី១២ នៃមធ្យមសិក្សាទុតិយភូមិ។ វិញ្ញាសាទាំងឡាយជាវិញ្ញាសាសរសេរទាំងអស់។

ប្រការ២០_ ប្រធានវិញ្ញាសាទាំងឡាយត្រូវជ្រើសរើស ឬ តាក់តែងដោយក្រសួងអប់រំ យុវជន និង កីឡា។

ប្រការ២១_ ប្រធានវិញ្ញាសាទាំងឡាយ ដែលបានជ្រើសរើសរួចហើយ ត្រូវដាក់ក្នុងស្រោមសំងាត់ បិទជិត និង ប្រថាប់ត្រា ហើយត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដែលមានមណ្ឌលប្រលងតាមរយៈមេប្រយោគទូទាំងប្រទេសអោយថែរក្សាទុកយ៉ាងតិច៣៦ម៉ោងមុនពេលប្រកាសចាប់ផ្តើមប្រលង។

ប្រការ២២_ អាជ្ញាធរមានសមត្ថកិច្ច ដែលថែរក្សាវិញ្ញាសាទាំងនោះ ត្រូវប្រគល់អោយគណៈមេប្រយោគទូទាំងប្រទេសនៅថ្ងៃចាប់ផ្តើមការប្រលងមួយម៉ោង មុនពេលបើកសម័យប្រលង។

ប្រការ២៣_ ការប្រគល់អោយ និង ការទទួលយកវិញ នូវប្រធានវិញ្ញាសាប្រលងត្រូវមានការទទួលខុសត្រូវទាំងសងខាង ដោយមានកំណត់ហេតុជាផ្លូវការផង។

ប្រការ២៤_ វិញ្ញាសានីមួយៗ ត្រូវមានចំនួនសន្លឹកវិញ្ញាសា ស្មើនឹងចំនួនបេក្ខជន។ បើខ្វះត្រូវចំលងបន្ថែមបង្គ្រប់ភ្លាម។

ប្រការ២៥- ដំនើរការកំនែត្រូវប្រព្រឹត្តទៅនៅមណ្ឌលកំនែប្រមូលផ្តុំនៅរាជធានីភ្នំពេញ។

ប្រការ២៦- មណ្ឌលកំនែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការមណ្ឌលកំនែដឹកនាំដោយប្រធានមួយនាក់។ប្រធានមណ្ឌលកំនែជាប្រធាន រឺអនុប្រធានមេប្រយោគទូទាំងប្រទេស។

ប្រការ២៧- បន្ទាប់ពីបញ្ចប់ដំនើរការវិញ្ញាសារសរសេរ មេប្រយោគទូទាំងប្រទេសប្រចាំខេត្ត-ក្រុងនីមួយៗ និង ប្រធានមណ្ឌលនៃមណ្ឌលសំនេរនីមួយៗ ត្រូវប្រមូលកិច្ចការបេក្ខជន និង កំនត់ហេតុដំនើរការវិញ្ញាសារសរសេរមកប្រគល់អោយប្រធានមណ្ឌលកំនែ។

ប្រការ២៨- ប្រធាន-អនុប្រធានមណ្ឌលសំនេរនីមួយៗ ត្រូវចូលរួមបន្តការងារនៅមណ្ឌលកំនែ និង អនុវត្តភារកិច្ចតាមការចាត់តាំងរបស់ប្រធានមណ្ឌលកំនែ ។

ប្រការ២៩- មណ្ឌលកំនែនីមួយៗត្រូវបែងចែកជាក្រុមមណ្ឌលមុខវិជ្ជា។

ប្រការ៣០- ប្រធាន-អនុប្រធានក្រុមមណ្ឌលមុខវិជ្ជាជ្រើសរើសក្នុងចំនោមគណៈមេប្រយោគទូទាំងប្រទេស ហើយចាំបាច់ត្រូវចុះលេខសំងាត់លើសន្លឹកកិច្ចការបេក្ខជន។

ប្រការ៣១- ពេលចប់កិច្ចការកំនែគ្រប់គណៈកម្មការនានាត្រូវរំសាយ។ ត្រូវបង្កើតគណៈកម្មការថ្មីមួយសំរាប់ស្រង់ប្ញកពិន្ទុដោយកុំព្យូទ័រ និង គណៈកម្មការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់លទ្ធផល។

ប្រការ៣២- ការស្រង់ប្ញកពិន្ទុដោយកុំព្យូទ័រ ប្រព្រឹត្តទៅនៅការិយាល័យប្រលង នៃនាយកដ្ឋានធ្យមសិក្សាចំនេះទូទៅ។

ប្រការ៣៣_ កិច្ចការបេក្ខជននីមួយៗ ត្រូវកែដោយសមាជិកកំនែពីរនាក់ជាដាច់ខាត តាមតារាង/

អត្រាកំនែ ដែលគណៈមេប្រយោគបានសំរេច។

ប្រការ៣៤_ ពិន្ទុសរុបនៃពិន្ទុគ្រប់មុខវិជ្ជា ហៅថាពិន្ទុប្រលងថ្នាក់ជាតិ ជាពិន្ទុលើ ៦០០ ។

ប្រការ៣៥_ ពិន្ទុប្រចាំឆ្នាំស្មើនឹងមធ្យមភាគពិន្ទុឆមាសទី១ បូកនឹងមធ្យមភាគពិន្ទុឆមាសទី២ ជាពិន្ទុលើ ១០០។

ប្រការ៣៦_ ពិន្ទុប្រចាំឆ្នាំតាមមុខវិជ្ជា ត្រូវធ្វើកំនែតំរូវជាមួយពិន្ទុប្រលងតាមមុខវិជ្ជា ដែលគេហៅថា " ពិន្ទុប្រចាំឆ្នាំកំនែតំរូវ " ។

ប្រការ៣៧_ ពិន្ទុប្រលងស្មើនឹងពិន្ទុប្រចាំឆ្នាំកំនែតំរូវ បូកនឹងពិន្ទុប្រលងថ្នាក់ជាតិ ។

ប្រការ៣៨_ នឹងត្រូវប្រកាសថាប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បេក្ខជននៃវិទ្យាល័យសាធារណៈ និងឯកជនទាំងឡាយណាដែលបានពិន្ទុប្រលងចាប់ពី៣៥០ឡើងទៅ និងបេក្ខជនស្វ័យរិនទាំងឡាយណាដែលបានពិន្ទុប្រលងថ្នាក់ជាតិចាប់ពី៣០០ឡើងទៅដោយឥតមានពិន្ទុសូន្យចំពោះវិញ្ញាសាណាមួយ។

ក្នុងករណីចាំបាច់ អាចធ្វើសំរង់អោយជាប់បន្ថែម ក្រោយពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាតាមភាពជាក់ស្តែង និងតាមសំនើរបស់គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល ។ បេក្ខជនស្វ័យរិនមិនធ្វើសំរង់អោយជាប់បន្ថែមឡើយ។

ប្រការ៣៩_ អគ្គនាយកអប់រំ មានភារកិច្ចចុះហត្ថលេខាលើតារាងស្រង់ពិន្ទុ និងបញ្ជីចុះជាប់ផ្លាក់សំរាប់បិទផ្សាយ។

ប្រការ៤០_ និទ្ទេសត្រូវបានកំនត់តាមពិន្ទុប្រលងដូចតទៅ ÷

* ចំពោះបេក្ខជននៃវិទ្យាល័យសាធារណៈ និង ឯកជន :

| និទ្ទេស | ពិន្ទុប្រលង | ភាគរយ |
|---|---|---|
| A | 630 - 700 | 90 - 100 % |
| B | 560 - 629 | 80 - 89,99 % |
| C | 490 - 559 | 70 - 79,99 % |
| D | 420 - 489 | 60 - 69,99 % |
| E | 350 - 419 | 50 - 59,99 % |

* ចំពោះបេក្ខជនស្វ័យរិន :

| និទ្ទេស | ពិន្ទុប្រលង | ភាគរយ |
|---|---|---|
| A | 540 - 600 | 90 - 100 % |
| B | 480 - 539 | 80 - 89,99 % |
| C | 420 - 479 | 70 - 79,99 % |
| D | 360 - 419 | 60 - 69,99 % |
| E | 300 - 359 | 50 - 59,99 % |

**ប្រការ៤១_** បទបញ្ញត្តិ ស្តីពីការរៀបចំប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ពីមុនៗទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៤២_** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន ដើម្បីអោយបាន សំរេចនូវប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០០២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**តុល ឡោះ**

<u>កន្លែងទទួល</u> :

_ទីស្តីការគណៈរដ្ឋមន្ត្រី
"<u>ដើម្បីសូមជ្រាបជាពត៌មាន</u>"

_សាលាខេត្ត_ក្រុង
_គ្រប់អង្គភាពនៃក្រសួងអប់រំ យុវជន និងកីឡា
"<u>ដើម្បីជ្រាបជាពត៌មាន និង ជួយសហការ</u>"

_មន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុង
"<u>ដើម្បីអនុវត្ត</u>"

_កាលប្បវត្តិ
_ឯកសារ_នា. មចទ.

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០៩៧ សជណ

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ជំរាបជូន**

- ឯកឧត្តម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន
- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ក្រុងប៉ៃលិន ក្រុងកែប
- ឯកឧត្តម អភិបាលខេត្ត-ក្រុង
- លោកស្នងការនគរបាលខេត្ត-ក្រុង

**កម្មវត្ថុ:** សេចក្តីជូនដំណឹងស្តីពីការអនុវត្តអនុក្រឹត្យលេខ ២៧ អ.ន.ក្រ បក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ក្រសួងមហាផ្ទៃមានកិត្តិយស សូមជំរាបឯកឧត្តម លោកជំទាវ អស់លោក ទាំងអស់អោយបានជ្រាបថា : ដើម្បីឆ្លើយតបទៅនិងសំណូមពរ នៃភារកិច្ច ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ក្នុងដំណាក់កាលបច្ចុប្បន្ន និងដើម្បីឱ្យសមស្របតួនាទីរបស់នគរបាលជាតិកម្ពុជាទៅនឹងបណ្តាប្រទេសនានានៅលើសកលលោក ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ : ២៧ អ.ន.ក្រ បក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ ។

ខ្លឹមសារអនុក្រឹត្យចែងថា :

- ត្រូវបានកែសំរួលអគ្គនាយកដ្ឋាននគរបាលជាតិ មកជាអគ្គស្នងការដ្ឋាននគរបាល-ជាតិ ចំណុះក្រសួងមហាផ្ទៃ ។
- ត្រូវបានកែសំរួលអគ្គនាយកនគរបាលជាតិ មកជា អគ្គស្នងការនគរបាលជាតិ ។

ក្រសួងមហាផ្ទៃ នឹងចាប់អនុវត្តប្រើប្រាស់នៅក្នុងលិខិតបទដ្ឋាននានាជាផ្លូវការ ចាប់ពីថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០២ តទៅ ។

អាស្រ័យដូចបានជំរាបខាងលើ សូមឯកឧត្តម លោកជំទាវ អស់លោកជារដ្ឋមន្ត្រី រដ្ឋលេ-ខាធិការគ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងស្នងការនគរបាលខេត្ត-

ក្រុងទាំងអស់មេត្តាជ្រាបជាពតិមាន ។

សូមឯកឧត្តម លោកជំទាវ អស់លោកទាំងអស់ ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

សហរដ្ឋមន្ត្រី

ស ខេង ឃួ-ហុកគ្រី

*ចំលងជូន*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ស្ថានទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ: ០០១ សហវ.ថវ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០២

# សារាចរ

## ស្តីពីការណែនាំអនុវត្តថវិការដ្ឋឆ្នាំ ២០០២

### I. សេចក្តីផ្តើម

១. ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ។

ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ និង អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ និង អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា ។

ផ្អែកលើមូលដ្ឋាននៃអនុក្រឹត្យខាងលើនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញប្រកាសលេខ ០០១ សហវ.ថហ.ប្រក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ និង ប្រកាសលេខ ០០២ សហវ.ថហ.ប្រក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

ដើម្បីឱ្យការអនុវត្តន៍ច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២នេះ ដំណើរការទៅប្រកបដោយលទ្ធផលល្អ និង មានប្រសិទ្ធិភាពខ្ពង់ខ្ពស់នោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំអនុវត្តថវិការដ្ឋឆ្នាំ ២០០២ មានដូចខាងក្រោមនេះ ៖

២. ជាបឋមចាំបាច់ត្រូវរំលឹកថា ថវិការដ្ឋឆ្នាំ ២០០២នេះ ត្រូវបានរៀបចំឡើងដល់ទៅពីរដង ។ ពេលព្រាងលើកទី ១ គឺឈរលើសម្មតិកម្ម Hypothèse នៃសភាពការណ៍សេដ្ឋកិច្ចក្នុងប្រទេស និង អន្តរជាតិ មុនព្រឹត្តិការណ៍ដ៏រន្ធត់ថ្ងៃទី ១១ ខែ កញ្ញា ។ ពេលកំពុងរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់លើកទី ១ នោះ ក្រសួង

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបង្ខំចិត្តសើរើ Hypothèse ឡើងវិញមុនដាក់ជូនគណៈរដ្ឋមន្ត្រី ក្រោយពីឃើញទំហំនៃបច្ច័យអាក្រក់ បន្ថែមលើឱនភាពសេដ្ឋកិច្ចសកលលោក ។ តាមការប៉ាន់ប្រមាណរបស់សេដ្ឋកិច្ចវិទូនានាថា សេដ្ឋកិច្ចសកលលោក នឹងមិនងើបឡើងវិញ មុនដំណាច់ត្រីមាសទី ២ ឆ្នាំ ២០០២ទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ថវិការដ្ឋឆ្នាំ ២០០២ ជាថវិកាដែលមានបង្ហាញនូវឆន្ទៈនយោបាយមោះមុត ក្នុងការបន្តអនុវត្តនូវកម្មវិធីនយោបាយ និង កម្មវិធីកំណែទំរង់លើគ្រប់ផ្នែករបស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទីពីរនេះ ។ ថវិការដ្ឋឆ្នាំ ២០០២នេះ មានជាគោលសំខាន់ៗ ដូចតទៅ ៖

ក) ដោយឈរលើមូលដ្ឋាន នៃការវិវត្តន៍ស្ថានភាពនយោបាយ និង យុទ្ធសាស្ត្រថវិការដ្ឋឆ្នាំ ២០០២ ឆ្លុះបញ្ចាំងនូវសភាពការណ៍សំខាន់ៗ ដូចតទៅ ៖

ទី១- ការបន្តអនុវត្ត នូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។

ទី២- ការបន្តអនុវត្ត នូវផែនការសកម្មភាពអភិបាលកិច្ច ។

ទី៣- ការបន្តអនុវត្ត នូវផែនការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង រចនាសម្ព័ន្ធសង្គម ។

ទី៤- ឆ្នាំ ២០០២ ជាឆ្នាំដ៏សំខាន់នៃការបន្តកំនែទំរង់ស៊ីជំរៅ របស់រាជរដ្ឋាភិបាល ពិសេសកម្មវិធីវិមជ្ឈការ ក្នុងនោះ មានចំណាយសំរាប់រៀបចំការបោះឆ្នោតឃុំ-សង្កាត់ ជាដើម ។

ខ) ថវិការដ្ឋឆ្នាំ ២០០២ គឺជាឧបករណ៍ដើម្បីធានាឱ្យបាន នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដែលជាគន្លឹះក្នុងការសំរេចឱ្យបាន នូវសមិទ្ធិផលសេដ្ឋកិច្ច និង សង្គមកិច្ចសំខាន់ៗ ។ ថវិការដ្ឋឆ្នាំ ២០០២ នឹងពង្រឹងចលនាការនៃកំណើន ដើម្បីសំរេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រកបដោយចិរភាព ។

គ) ពង្រឹងការកៀងគរធនធានហិរញ្ញវត្ថុបន្ថែមទៀត ទាំងចំណូលសារពើពន្ធ និង ចំណូលពុំមែនសារពើពន្ធ ដើម្បីសំរេចឱ្យបាននូវការប្រមូលចំណូលក្នុងស្រុក ចំនួន **១៣%នៃផសស** តាមការគ្រោងទុក ។ រាជរដ្ឋាភិបាល នឹងបន្តធ្វើវិចារណកម្មលើអាទិភាពចំណាយ ដោយផ្តោតជាសំខាន់លើការបង្កើនចំណាយសំរាប់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និង សង្គមកិច្ច ជាពិសេសវិស័យអប់រំ សុខាភិបាល កសិកម្ម និង អភិវឌ្ឍន៍ជនបទ ដើម្បីសំរេចឱ្យបាននូវ គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធនឹងភាពក្រីក្រ ។

ឃ) ពង្រឹង និង ពន្លឿនការអនុវត្តន៍នូវកម្មវិធីកាត់រំសាយកងទ័ព ក្នុងគោលដៅដែលជាការចាប់ផ្តើមការបង្វែរ ពីចំណាយការពារប្រទេស ទៅចំណាយសំរាប់ការអភិវឌ្ឍន៍វិស័យសង្គមកិច្ច និង សេដ្ឋកិច្ច ។ ដើម្បីសំរេចបាននូវទិសដៅនេះ រាជរដ្ឋាភិបាល នឹងអនុវត្តឱ្យបានស៊ីជំរៅនូវកំណែទំរង់រចនាសម្ព័ន្ធ ដោយកាត់បន្ថយកងទ័ពក្នុងកងយោធពលខេមរៈភូមិន្ទ និង ធ្វើកំនែទំរង់កងទ័ព ដើម្បីអនុវត្តនូវឯកសារ **"សៀវភៅសការពារជាតិ"** ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងចូលរួមចំណែក តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភ សំរាប់យោធិន ដែលត្រូវកាត់រំសាយ ។

– ក្នុងរយៈពេលចាប់ពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ នៃខែចុងត្រីមាសមុន នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច ត្រូវប្រជុំពិភាក្សាជាមួយនាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ និង នាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល ចំណាយថវិការដ្ឋ សំរាប់ត្រីមាសបន្ទាប់ ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើប្រកាសប្រគល់កម្មវិធីចំណូល ចំណាយសំរាប់ត្រីមាសបន្ទាប់ តាមជំពូកថវិកា ក្នុងករិតឥណទានអតិបរិមា ជូនដល់ក្រសួងស្ថាប័ននិមួយៗ និង មន្ទីរជំនាញខេត្ត-ក្រុងនិមួយៗ ដោយចម្លងជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រតនាគារ និង អភិបាលខេត្ត-ក្រុង ។

– ក្រសួងស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ចំណូល ចំណាយ ប្រចាំខែ ប្រចាំត្រីមាស ផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ ដូចមាន ចែងក្នុងមាត្រា ១៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

– អាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធ ត្រូវចេញអាណត្តិបើកប្រាក់ នៅក្នុងវង្វង់ នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង រតនាគារ ត្រូវចុះទិដ្ឋាការលើ អាណត្តិបើកប្រាក់ និង ត្រូវបើកផ្តល់សាច់ប្រាក់ តែនៅក្នុងករិតនៃកម្មវិធីប្រចាំត្រីមាសនេះ តែប៉ុណ្ណោះ ។ ក្នុងករណីមានការចាំបាច់ សុំបើកផ្តល់បន្ថែម ត្រូវធ្វើឡើងតាមប្រកាសផ្តល់កម្មវិធីបន្ថែម របស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅក្នុងក្របខ័ណ្ឌឥណទានថវិកា ដែលមិនទាន់បែងចែកទៅក្នុងកម្មវិធីចំណាយ ។

– រតនាគារត្រូវបញ្ជូនមក នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច នូវរបាយការណ៍បេឡាប្រចាំថ្ងៃ របាយការណ៍ចំណូល ចំណាយថវិកាប្រចាំខែ ព្រមទាំងសាលាកប័ត្របង់ប្រាក់ និង តារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតំលៃនូវ សភាពការណ៍អនុវត្ត ប្រៀបធៀបនឹងខែមុន ត្រីមាសមុន នៃឆ្នាំនេះ និង ប្រៀបធៀបនឹងខែ ត្រីមាសដូចគ្នា នៃឆ្នាំមុន ។

## VII. អំពីចលនាឥណទានថវិកា

១៨. ក្រសួងស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួន ទៅតាមប្រកាស របស់ក្រសួសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចមានលំអិតនៅក្នុងសៀវភៅថវិកា ។ ក្នុងករណីដែលមានខ្ទង់ថវិកាណា មួយមិនគ្រប់ តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាព មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យសំរេច ។ បើក្រសួងស្ថាប័ន មានសំណូមពរផ្តល់ឥណទានបន្ថែម ដូចជាចំណាយ ដំណើរការរដ្ឋបាល សំភារៈ ការជួសជុលតូច ការសាងសង់ និង ទព្វសំភារៈ ។ល។ ទៅឱ្យមន្ទីរជំនាញរបស់ខ្លួន នៅខេត្ត-ក្រុង នោះគឺ ត្រូវធ្វើឡើងដោយប្រកាសផ្ទេរឥណទាន របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឱ្យអភិបាលខេត្ត-ក្រុង ( អាណាប័កតាមការប្រទានសិទ្ធ) ដែលជាខ្សែទទឹង និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចតាមដានការ

ប្រើប្រាស់ឥណទានថវិកា បន្ថែមទាំងនោះបាន ។ ចំពោះការស្នើសុំនិយ័តភាពឥណទានថវិកា នៅផ្ទៃក្នុង ក្រសួងស្ថាប័ន និង មន្ទីរជំនាញខេត្ត ក្រុង នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០០២នេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនពិនិត្យសំរេចអនុញ្ញាតជូនទេ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមលើការយកចិត្តទុកដាក់ របស់ក្រសួងស្ថាប័ន និង ខេត្ត-ក្រុង ក្នុងការអនុវត្តន៍ថវិកាឆ្នាំ ២០០២ ប្រកបដោយលទ្ធផលល្អប្រសើរ ទៅតាមកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន**

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  (ដើម្បីជ្រាបជាពត៌មាន)
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់ខេត្ត ក្រុង
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ២០៤ សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

  បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៦៦ សហវ.ប្រក.ប ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០១
- ផ្អែកលើលក្ខណៈចាំបាច់ នៃសំណូមពរការងារ នៃកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ដែលមានមន្ត្រីជាសមាជិកដូចមាននាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ជូ គីមឡេង | អគ្គលេខាធិការរង | ប្រធាន |
| ២- លោក | ឋិន ឃន | ប្រធានរតនាគារជាតិ | អនុប្រធាន |
| ៣- លោក | ទូច ឡេង | ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច | អនុប្រធាន |
| ៤- លោក | ហ៊ីវ សុវណ្ណ | អនុប្រធានរតនាគារជាតិ | សមាជិក |
| ៥- លោក | ម៉ឹង ស៊ឹម | អនុប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច | សមាជិក |

| | | | |
|---|---|---|---|
| ៦- លោក | ឈឹម សារ៉េត | អនុប្រធានរតនាគារជាតិ | សមាជិក |
| ៧- លោក | ស៊ាន ម៉ាឡូត | ប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ | សមាជិក |
| ៨- លោក | ប៉ែន ចាន់លី | ប្រធានការិយាល័យស្រាវជ្រាវរតនាគារជាតិ | សមាជិក |
| ៩- លោក | ឈាន ហ៊ាង | ប្រធានការិយាល័យគណនេយ្យរតនាគារជាតិ | សមាជិក |
| ១០-លោកស្រី | ស៊ុន ណាលី | ប្រធានការិយាល័យគ្រប់គ្រងបំណុល នៃនាយកដ្ឋាន វិនិយោគ និង សហប្រតិបត្តិការ | សមាជិកា |
| ១១- លោក | អ៊ិន សុមេធ | ប្រធានការិ.វិភាគថវិកា នា.វិភាគនិងព្យាករណ៍សេដ្ឋកិច្ច | សមាជិក |
| ១២- លោក | ទា សេ | អនុប្រធានក្តាប់រួមការិ.គ្រប់គ្រងថវិការដ្ឋបាលកណ្តាល | សមាជិក |

**ប្រការ២ :** គណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ត្រូវទទួលបន្ទុករៀបចំផែនការព្យាករណ៍សាច់ប្រាក់ប្រចាំឆ្នាំដោយផ្អែកលើតុល្យភាពទូទៅរវាងចំណូល និង ចំណាយថវិកា ។ ផែនការព្យាករណ៍សាច់ប្រាក់នេះ ត្រូវកំណត់ :

- ចំនួនទឹកប្រាក់ សំរាប់ទូទាត់ចំណាយប្រចាំខែ រួមទាំងអាណត្តិនៅសល់មិនអាចទូទាត់បាននាចុងឆ្នាំមុន ។ ចំណាយទាំងនេះ ត្រូវបែងចែកតាមលំដាប់នៃអាទិភាពៈ ចំណាយជាកាតព្វកិច្ច ចំណាយអាទិភាព ចំណាយផ្សេងៗ ចំណាយវិនិយោគ អាណត្តិនៅសល់ពីមុនត្រូវទូទាត់បន្ត

- តំរូវការនៃហិរញ្ញប្បទាន ចំពោះឱនភាពជាយថាហេតុ រវាងលំហូរនៃចំណូល និង លំហូរនៃចំណាយ

- មធ្យោបាយនៃហិរញ្ញប្បទាន ចំពោះឱនភាពនេះ ជាយថាហេតុនៅពេលអនាគតដោយប្រើប្រាស់សមតុល្យរតនាគារ (សមតុល្យគណនីបេឡា និង គណនីរតនាគារនៅធនាគារ) ព្រមទាំងបុរេសមុច្ចេទន៍ពីគណនីនានាដែលជាចំណូលថវិការដ្ឋ បើកនៅធនាគារជាតិនៃកម្ពុជា។ ការធ្វើបុរេសមុច្ចេទន៍ទាំងនេះនឹងប្រព្រឹត្តទៅ ក្រោយពេលសមាហរណកម្មពេញលេញនៃសាច់ប្រាក់របស់រដ្ឋដែលត្រូវគ្រប់គ្រងដោយរតនាគារជាតិ ។

**ប្រការ៣ :** គណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ត្រូវពិនិត្យលទ្ធភាពសងបំណុលធនាគារជាតិនៃកម្ពុជា ដើម្បីបន្ថយបន្ទុកការប្រាក់និងធ្វើការចរចាជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីព្រមព្រៀងគ្នា បន្ថយអត្រាការប្រាក់ និងរៀបចំធ្វើបញ្ជីសងបំណុល ទៅតាមកាលវសានច្រើនឆ្នាំ។

**ប្រការ៤ :** គណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ត្រូវធ្វើការប្រជុំជាសាមញ្ញមួយដងក្នុងមួយខែ ដើម្បី :

- រៀបចំ និង បង្កើតផែនការព្យាករណ៍សាច់ប្រាក់ប្រចាំឆ្នាំ និង ប្រចាំខែ

- ប្រៀបធៀប ការប៉ាន់ស្មានសាច់ប្រាក់ ជាមួយការអនុវត្តន៍ជាក់ស្តែង ព្រមទាំងលើកវិធានការដោះស្រាយចំពោះការលំបាកសាច់ប្រាក់ ជាយថាហេតុ ។ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការអាចកោះប្រជុំវិសាមញ្ញបាន ។

**ប្រការ៥ :** គណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ត្រូវធ្វើរបាយការណ៍ស្តីពីការគ្រប់គ្រងនិងផែនការសាច់ប្រាក់ជាប្រចាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បី ពិនិត្យណែនាំ ឬ / និងសំរេច សំរាប់ឱ្យការអនុវត្តមានប្រសិទ្ធិភាពខ្ពស់ ។

ប្រការ៦ : ត្រូវបានបង្កើតអនុគណៈកម្មាធិការចំនួន ២ ចំណុះគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ រួមមាន :

- អនុគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់
- អនុគណៈកម្មាធិការគ្រប់គ្រងចំណូល ចំណាយ

ប្រការ៧ : អនុគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់ រួមមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- លោក | ហ៊ីវ សុវណ្ណ | អនុប្រធានរតនាគារជាតិ | ប្រធាន |
| ២- លោក | ឈឹម សារ៉េត | អនុប្រធានរតនាគារជាតិ | អនុប្រធាន |
| ៣- លោក | ប៉ែន ចាន់លី | ប្រធានការិយាល័យស្រាវជ្រាវរតនាគារជាតិ | សមាជិក |
| ៤- លោក | ឈាន ហ៊ាង | ប្រធានការិយាល័យគណនេយ្យរតនាគារជាតិ | សមាជិក |
| ៥- លោក | ស៊ាន ម៉ាឡូត | ប្រធានអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ | សមាជិក |

ប្រការ៨ : អនុគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់ ត្រូវធ្វើការប្រជុំយ៉ាងហោចណាស់មួយសប្តាហ៍ម្តង ដើម្បីពិនិត្យស្ថានភាពសាច់ប្រាក់ពិតប្រាកដរបស់រដ្ឋដោយផ្អែកលើស្ថានភាពសមតុល្យបេឡា និង នៅធនាគារ រួមទាំងគណនីចំណូលថវិការដ្ឋនៅធនាគារជាតិនៃកម្ពុជា ដែលអាចធ្វើហិរញ្ញប្បទានអោយចំណាយរបស់រដ្ឋ ។ អនុគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់ត្រូវទទួលបន្ទុកតាមដានការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃធានាលំហូរចូល នៃសាច់ប្រាក់ដើម្បីទូទាត់ចំណាយរបស់រដ្ឋ (អាណត្តិបោះផ្សាយនិងបញ្ជូនទៅដល់រតនាគារ និង បុរេប្រទានដែលមានចែងក្នុងបទបញ្ញត្តិ) ។ ប្រសិនបើលំហូរចូល នៃសាច់ប្រាក់ក្នុងគណនីមិនគ្រប់គ្រាន់សំរាប់ទូទាត់ចំណាយ អនុគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់ត្រូវលើកវិធានការទូទាត់ចំណាយតាមលំដាប់អាទិភាពស្របតាមកាតព្វកិច្ចថវិកា និងតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ប្រការ៩ : អនុគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់ ត្រូវកំណត់តំរូវការហិរញ្ញប្បទានប្រចាំថ្ងៃសំរាប់ចំណាយរបស់រដ្ឋ នៅរដ្ឋបាលកណ្តាល ព្រមទាំងតំរូវការហិរញ្ញប្បទានប្រចាំខែសំរាប់ចំណាយសេវារបស់រដ្ឋ និង សេវា របស់អភិបាលខេត្ត ក្រុង ។ អនុគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់រៀបចំ :

-ស្ថានភាពសាច់ប្រាក់ប្រចាំថ្ងៃសំរាប់រដ្ឋបាលកណ្តាល និងប្រចាំខែសំរាប់សេវាខេត្ត ក្រុង ដើម្បីទូទាត់ចំណាយរបស់រដ្ឋដោយផ្អែកលើសាច់ប្រាក់នៅបេឡានិងនៅធនាគារ ។

- ស្ថានភាពលំហូរចេញនិងចូលនៃសាច់ប្រាក់ ដែលបានអនុវត្តជាក់ស្តែងក្នុងខែហើយស្របតាមប្រតិបត្តិការថវិកា ។

ប្រការ១០: អនុគណៈកម្មាធិការគ្រប់គ្រងចំណូលចំណាយថវិកា រួមមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោក | ម៉ឹង ស៊ីម | អនុប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច | ប្រធាន |
| ២-លោក | ទា សេ | អនុប្រធានក្តាប់រួមការិ.គ្រប់គ្រងថវិការដ្ឋបាលកណ្តាល | អនុប្រធាន |
| ៣- កញ្ញា | ស៊ុន ណាលី | ប្រធានការិយាល័យគ្រប់គ្រងបំណុល | សមាជិកា |
| ៤-លោក | ស៊ិន ណុយ | ប្រធានការិយាល័យគ្រប់គ្រងថវិកាសាលាខេត្ត ក្រុង | សមាជិក |
| ៥-លោក | ស៊ុន ស៊ីដេត | មន្ត្រីអង្គភាពគ្រប់គ្រងរូបិយប័ណ្ណ | សមាជិក |

**ប្រការ១១:** អនុគណៈកម្មាធិការគ្រប់គ្រងចំណូលចំណាយត្រូវធ្វើការប្រជុំយ៉ាងហោចណាស់មួយសប្ដាហ៍ម្ដង ដើម្បីពិនិត្យស្ថានភាពចំណូល ចំណាយថវិកាតាមដាន ការសន្យាចំណាយ ការបោះផ្សាយអាណត្តិ ការធ្វើបុរេប្រទាន ការទូទាត់ប្រាក់បុរេប្រទាន ។ ប្រសិនបើមានអាណត្តិកកស្ទះនៅរតនាគារជាតិ ដោយសារមូលហេតុលំហូរសាច់ប្រាក់ចូលក្នុងគណនីមិនគ្រប់គ្រាន់សំរាប់ទូទាត់ចំណាយ អនុគណៈកម្មាធិការគ្រប់គ្រងចំណូលចំណាយ ត្រូវលើកវិធានការ ផ្អាកការបោះផ្សាយអាណត្តិដែលធ្វើឡើងដោយអាណាប័ក បន្ថយការសន្យាចំណាយ ដាក់វិធានការជំរុញបង់ចំណូល ឬលើកជាសំណើខ្ចីសាច់ប្រាក់ជាបណ្ដោះអាសន្នជូនគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យនិងសំរេច ។ តារាងគំរូនៃផែនការសាច់ប្រាក់ដែលភ្ជាប់មកជាមួយប្រកាសនេះ ត្រូវបានបំពេញតួលេខ ពីតារាងនានា ដែលរៀបចំដោយអនុគណៈកម្មាធិការគ្រប់គ្រងចំណូល ចំណាយ ។

**ប្រការ១២:** ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ អាចអញ្ជើញមន្ត្រី ក្នុង និងក្រៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលពាក់ព័ន្ធអំពីថវិកាសាច់ប្រាក់ ដើម្បីចូលរួមប្រជុំ ។

**ប្រការ១៣:** រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានាយកដ្ឋានបុគ្គលិក គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចប្រការ ១. ៧ និង ១០ ខាងលើត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល:</u>

- គ្រប់ថ្នាក់ដឹកនាំនៃ ស.ហ.វ
- គ្រប់នាយកដ្ឋានក្រោមឱវាទ ស.ហ.វ
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៥២ សហវ.អ

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០២

# សូមទូលថ្វាយ-គោរពជូន

## សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ
## ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន
## ប្រតិភូរាជរដ្ឋាភិបាល អភិបាល គ្រប់ខេត្ត-ក្រុង

**កម្មវត្ថុ** : ស្តីពីកម្មវិធីនៃកិច្ចប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ ២០០២

**យោង** : -ព្រះរាជក្រមលេខ ០១នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងក្នុងឆ្នាំ ១៩៩៩ ដែលត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ ១១នស/៩៤ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងក្នុងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩

- បានឃើញ ច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងក្នុងឆ្នាំ ២០០១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០
- បានឃើញ ខ្លឹមសារមាត្រា ៧ នៃអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ផ្អែកតាមភារកិច្ចចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

តបតាមកម្មវត្ថុនិងយោងដូចមានចែងខាងលើ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមទូលថ្វាយ-គោរពជូន សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ និង ប្រតិភូរាជរដ្ឋាភិបាល អភិបាល គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង មេត្តាជ្រាបថា : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាន រៀបចំកម្មវិធីនៃកិច្ចប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ ២០០២ ដែលមានជាអាទិ៍ដូចខាងក្រោម :

### ក- ភារងារអធិការកិច្ចហិរញ្ញវត្ថុជាប្រចាំ :

ក្នុងគោលបំណងពង្រឹងការងារគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមបណ្តាក្រសួង ស្ថាប័ន សហគ្រាស

សាធារណៈ និង បណ្តាខេត្តក្រុងឱ្យមានតម្លាភាព និង ការទទួលខុសត្រូវ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានគំរោង នឹងរៀបចំធ្វើអធិការកិច្ចតាមបណ្តាមុខព្រួញសំខាន់ៗដូចខាងក្រោម :

១- ធ្វើអធិការកិច្ចការគ្រប់គ្រង និង ការប្រើប្រាស់ទុនអចល័ត " អចលនវត្ថុជួល ម៉ៅការ លក់ បែងចែកនិងការផ្ទេរ " របស់បណ្តាក្រសួង ស្ថាប័នរដ្ឋ សំដៅធានាចំណូលពីការជួល និង លក់អចលនទ្រព្យ បង់ចូលថវិការដ្ឋ និង រក្សាការពារទ្រព្យសម្បត្តិរដ្ឋឱ្យបានគង់វង់ ។

២- ធ្វើអធិការកិច្ចការគ្រប់គ្រង និងការប្រើប្រាស់ទុន ព្រមទាំងការអនុវត្តនីវិន័យបង់ចូលថវិការដ្ឋរបស់បណ្តាសហគ្រាសសាធារណៈ គ្រឹស្ថានសាធារណៈ ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចំរុះរដ្ឋឯកជន ។

៣- ធ្វើអធិការកិច្ចការអនុវត្តន៍គំរោងចំណូល-ចំណាយថវិកាចំពោះបណ្តាអង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងស្ថាប័ន និង មន្ទីររដ្ឋបាលខេត្ត-ក្រុង ។

៤- ធ្វើអធិការកិច្ចរាល់ការចំណាយវិនិយោគរបស់រដ្ឋ និង លទ្ធកម្មសាធារណៈ ។

៥- ធ្វើអធិការកិច្ចការប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និងរដ្ឋាករ ព្រមទាំងបណ្តាសាខា-ស្នាក់ការ ( ពន្ធដារ និង គយរដ្ឋាករ ) តាមបណ្តាខេត្ត-ក្រុង ។

៦- ធ្វើអធិការកិច្ចការគ្រប់គ្រងចំណូល និងការបែងចែកថវិការបស់រតនាគារជាតិ នឹងរតនាគារខេត្ត-ក្រុង ។

៧- ធ្វើអធិការកិច្ចការគ្រប់គ្រងចំណូលពុំមែនសារពើពន្ធរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមបណ្តាខេត្ត-ក្រុង ។

៨- ធ្វើការត្រួតពិនិត្យសារឡើងវិញនៅតាមបណ្តាអង្គភាពដែលបានធ្វើអធិការកិច្ចរួចហើយដើម្បីក្តាប់បាននូវលេទ្ធផលនៃការអនុវត្តន៍កែលំអតាមសំណូមពររបស់អធិការកិច្ចដែលបានលើកឡើង ។

៩- ធ្វើអធិការកិច្ច ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC ) និង ក្រុមហ៊ុនវិនិយោគឯកជនព្រមទាំងអង្គការក្រៅរដ្ឋាភិបាល (NGO ) ដែលមិនរកប្រាក់ចំណេញនានា និង បានទទួលផលប្រយោជន៍ដោយផ្ទាល់ ឬ ដោយប្រយោលពីរាជរដ្ឋាភិបាល ។

១០- ធ្វើអធិការកិច្ចលើអង្គភាពប្រតិបត្តិគំរោង( PIU ) នៅតាមបណ្តាក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដែលបានទទួលការផ្តល់ជំនួយ និង កម្ចីឥណទានពីអង្គការអន្តរជាតិផ្សេងៗ ដោយផ្តោតជាសំខាន់លើការប្រើប្រាស់ថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ។

១១- ធ្វើអធិការកិច្ចលើអង្គភាពប្រតិបត្តិគំរោងកម្មវិធីសកម្មភាពជាអាទិភាព (PAP ) ដែលបានទទួលការគ្រប់គ្រងថវិកាពីអង្គភាពយុទ្ធសាស្ត្រ និងគ្រប់គ្រងការអនុវត្តន៍ថវិកា (BSEC ) ។

១២- ធ្វើអធិការកិច្ចលើក្រុមហ៊ុនធានារ៉ាប់រងជាតិ និង ស្ថាប័នហិរញ្ញវត្ថុ ។

១៣- ធ្វើអធិការកិច្ចដោះស្រាយរាល់ពាក្យបណ្តឹងតវ៉ា បរិហារ ដែលពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុ ។

១៤- ធ្វើអធិការកិច្ចលើការគ្រប់គ្រងរូបិយវត្ថុ និង រូបិយប័ណ្ណរបស់ធនាគារជាតិក្នុងករណីចូលរួមជាមួយគណកម្មការពិសេសរបស់រាជរដ្ឋាភិបាល ។

ខ. ត្រៀមលក្ខណៈធ្វើអធិការកិច្ចចៃដន្យ :

- តាមសំណូមពររបស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងសហគ្រាសសាធារណៈ
- តាមតម្រូវការជាក់ស្តែងនៃការងារ
- តាមការណែនាំរបស់រាជរដ្ឋាភិបាល
- សហការជាមួយអាជ្ញាធរសវនកម្មជាតិ

សេចក្តីដូចបានទូលថ្វាយ និង ជំរាបជូនក្នុងកម្មវិធីនៃកិច្ចប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុខាងលើ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ គ្រប់ក្រសួង ស្ថាប័ន និងប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង មេត្តាជ្រាបជាពត៌មាន និងមេត្តាចូលរួមសហការ ឱ្យបានសំរេចជោគជ័យ ។

សូមសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ឯកសារ-កាលប្បវត្តិ